សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of law and Economics

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលឃុំកោពព្រាំ
# ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

ស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **កញ្ញា រី តីរ៉ា**
**លោក រឿន ឧត្តម**

សាស្ត្រាចារ្យណែនាំ
**បណ្ឌិត សឿន សោភ័ណ**

ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ
ជំនាន់ទី ១១
ឆ្នាំចូលសិក្សា ២០១៤
ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

ជាបឋមយើងខ្ញុំ **រី តីរ៉ា** និង **រឿន ឧត្តម** ជានិស្សិតជំនាន់ទី១១ ផ្នែករដ្ឋបាលសាធារណៈនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ យើងខ្ញុំទាំងពីរសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- **លោកអ្នកមានគុណទាំងពីរ** ដែលបានចិញ្ចឹមបីបាច់ថែរក្សា ការពារ ទំនុកបម្រុងសព្វគ្រប់បែបយ៉ាង អប់រំ ផ្តល់ដំបូន្មានល្អៗ និងបញ្ជូនកូនអោយបានសិក្សារៀនសូត្ររហូតមកដល់សព្វថ្ងៃ ផ្តល់ទាំងថវិកា សម្ភារ: និងកំលាំងចិត្តដល់យើងខ្ញុំទាំងពីរ ។

- **ឯកឧត្តមសកលវិទ្យាធិការ ក៏ដូចជាសកលវិទ្យាធិការរង លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យ** គ្រប់រូបនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបូជានូវកម្លាំងកាយចិត្ត និងស្មារតីខិតខំបង្ហាត់បង្ហាញដល់និស្សិតគ្រប់រូបដោយទឹកចិត្តមេត្តាករុណាបំផុត ។

- លោកសាស្ត្រាចារ្យ**បណ្ឌិត សឿន សោភ័ណ** ដែលជាសាស្ត្រាចារ្យណែនាំ ដែលបានចំនាយពេលវេលាដល់មានតម្លៃក្នុងការផ្តល់យោបល់ ផ្តល់ដំបូន្មានល្អៗ និងការត្រួតពិនិត្យសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំទាំងពីរនាក់យ៉ាងយកចិត្តទុកដាក់ ។

- លោក **អ៊ុំ ដា** ដែលជាប្រធានក្រុមប្រឹក្សាឃុំរកាពប្រាំ និងមន្ត្រីរាជការទាំងអស់នៅឃុំរកាពប្រាំ ជាពិសេសលើក **អ៊ុំ ដារ៉ូត** ដែលជាជំទប់ទី១ នៃឃុំរកាពប្រាំដែលលោកបានចំនាយពេលវេលាដ៏មានតម្លៃផ្តល់ជាយោបល់ និងផ្តល់នៃឯកសារផ្សេងៗដែលជាជំនួយក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំទាំងពីរ ។

- **មិត្តរួមថ្នាក់ និងរួមជំនាន់ជាមួយគ្នាទាំងអស់**ដែលបានជំរុញលើកទឹកចិត្ត និងការពិភាក្សាផ្លាស់ប្តូរយោបល់ ផ្លាស់ប្តូរចំណេះដឹង រួមទាំងបទពិសោធន៍ល្អៗក្នុងការពង្រឹងពង្រីកចំនេះដឹងបន្ថែមទៀត ។

ជាកិច្ចចុងក្រោយយើងខ្ញុំទាំងពីរសូមគោរពជូនពរចំពោះអ្នកមានគុណទាំងអស់ខាងលើអោយជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ពិតជាមានសារៈសំខាន់ណាស់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សង្គមជាតិទាំងមូលឱ្យមានការរីកចម្រើន។ លើសពីនេះទៅទៀត ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ លើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ បង្កើនសុខុមាលភាព និង ឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ហើយធ្វើឱ្យរដ្ឋាភិបាល និងប្រជាពលរដ្ឋកាន់តែមានភាពជិតស្និតនិងគ្នា មិនតែប៉ុណ្ណោះយល់កាន់តែច្បាស់អំពីតម្រូវការរបស់ប្រជាពលរដ្ឋថាពួកគាត់ចង់បានអី និងមិនចង់បានអី និងងាយស្រួលក្នុងការជួយដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋបានទាន់ពេលវេលា ។

អាស្រ័យដូចបានរៀបរាប់ខាងលើនេះរួចមកហើយ កត្តាទាំងអស់នេះហើយទើបធ្វើអោយយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទ ការគ្រប់គ្រងរដ្ឋបាលឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ យកមកសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ ព្រោះប្រធានបទនេះអាចឱ្យយើងមើលឃើញជាក់ស្តែងពីការអនុវត្តនូវការគ្រប់គ្រងរដ្ឋបាលថ្នាក់ឃុំ សង្កាត់ថាអាចអនុវត្តន៍ទៅបានរលូនដែរទេ និងឃើញអំពីការអនុវត្តតួនាទី ភារកិច្ចរបស់មន្ត្រីថ្នាក់ឃុំ សង្កាត់ថាគោរពតាមគោលការណ៍នៃបទដ្ឋានគតិយុត្តនានាដែរ ឬទេ ។ ម្យ៉ាងវិញទៀតព្រោះយើងខ្ញុំទាំងពីរចង់បង្ហាញអោយមិត្តអ្នកអានបានដឹងអោយកាន់តែច្បាស់អំពីការងារ និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីជួយជាប្រយោជន៍ដល់មិត្តអ្នកអាននៅកាលៈទេសៈចាំបាច់ណាមួយ ។

តាមរយៈកិច្ចស្រាវជ្រាវនេះ បើទោះបីជាយើងខ្ញុំបានខិតខំប្រឹងប្រែង ស្រាវជ្រាវតាមរយៈឯកសារគោលនានា ក៏ដូចជាឯកសារដែលបានមកពីថ្នាក់មូលដ្ឋានឃុំ និងឯកសារផ្សេងទៀតក្តីកិច្ចស្រាវជ្រាវនេះគង់តែនឹងមាននៅចំណុចខ្វះខាត និងកំហុសខុសឆ្គងត្រង់កន្លែងណាមួយជាក់ជាពុំខានឡើយទាំងផ្នែកខឹមសារ អក្ខរាវិរុទ្ធ និងអត្ថបទ។ យើងខ្ញុំរីករាយ និងរង់ចាំទទួលនូវការរិះគន់ស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តនិស្សិត និងមិត្តអ្នកអានគ្រប់រូបដើម្បីកែលម្អអោយកាន់តែប្រសើរនៅពេលក្រោយៗទៀត។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

១.លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២.ចំនោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣.គោលបំណងនៃការស្រាវជ្រាវ ........ ២

៤.ដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥.វិធីសាស្រ្តស្រាវជ្រាវ ........ ៣

៦.រចនាសម្ពន្ធ័នៃការស្រាវជ្រាវ ........ ៣

**ជំពូកទី១៖ ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលឃុំ សង្កាត់** ........ ៤

១.១.ការរៀបចំរដ្ឋបាលឃុំ សង្កាត់ ........ ៤

១.១.១.ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ........ ៤

១.១.២.រចនាសម្ពន្ធ័នៃរដ្ឋបាលឃុំ សង្កាត់ ........ ៥

១.១.៣.សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់ ........ ៧

១.១.៤.តួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ សង្កាត់ ........ ៧

១.១.៥.តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ ........ ៩

១.២.កិច្ចការរដ្ឋបាលរបស់ឃុំ សង្កាត់ ........ ១២

១.២.១.លិខិតបទដ្ឋានគតិយុត្តឃុំ សង្កាត់ ........ ១២

១.២.២.លិខិតរដ្ឋបាលឃុំ សង្កាត់ ........ ១៣

១.២.៣.ការគ្រប់គ្រងបុគ្គលិករបស់ឃុំ សង្កាត់ ............ ១៥

១.២.៤.ការគ្រប់គ្រងឯកសាររបស់ឃុំ សង្កាត់ ............ ១៥

១.២.៥.ការគ្រប់គ្រងសម្ភារៈបរិក្ខាឃុំ សង្កាត់ ............ ១៥

១.២.៦.ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ............ ១៦

**ជំពូកទី២៖ ដំណើរការនៃការគ្រប់គ្រងរដ្ឋបាលឃុំរកាពប្រាំ** ............ ១៧

២.១.ស្ថានភាពភូមិសាស្ត្រ ............ ១៧

២.២.ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំ ............ ១៧

២.២.១.ការរៀបចំ និងការអនុម័តថវិកាឃុំ ............ ១៨

២.២.២.ចំណូល និងចំណាយថវិការបស់ឃុំ ............ ១៨

២.២.៣.ប្រព័ន្ធទូទាត់ គណនេយ្យ និងកិច្ចលទ្ធកម្មឃុំ សង្កាត់ ............ ២០

២.៣.ការអភិវឌ្ឍរបស់ឃុំរកាពប្រាំ ............ ២១

២.៣.១.ផែនការអភិវឌ្ឍន៍ឃុំ ............ ២១

២.៣.២.កម្មវិធីវិនិយោគរបស់ឃុំ ............ ២៥

**ជំពូកទី៣ ៖ បញ្ហាប្រឈម និងដំណោះស្រាយ** ............ ២៨

៣.១.បញ្ហាប្រឈម ............ ២៨

៣.១.១.ផ្នែកកសិកម្ម និងដីធ្លី ............ ២៨

៣.១.២.ផ្នែកគមនាគមន៍ ............ ២៨

៣.១.៣.ផ្នែកសេវាកម្មសុខាភិបាល និងបរិស្ថាន ............ ២៨

៣.១.៤.ផ្នែកអប់រំ ............ ២៩

៣.១.៥.ផ្នែកសន្តិសុខ និងសណ្តាប់ធ្នាប់ ............ ៣០

៣.១.៦.ផ្នែកការងាររដ្ឋបាល និងការចូលរួមរបស់ប្រជាពលរដ្ឋ ............ ៣០

៣.២.ដំណោះស្រាយ ............ ៣០

៣.២.១.ការពង្រឹងវិស័យកសិកម្ម និងដីធ្លី............ ៣០

៣.២.២.ការកែលម្អប្រព័ន្ធគមនាគម ............ ៣១

៣.២.៣.ការថែទាំសេវាសុខាភិបាលនិងបរិស្ថាន............ ៣១

៣.២.៤.ការលើកកម្ពស់គុណភាពអប់រំ ............ ៣២

៣.២.៥.ការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់............ ៣២

៣.២.៦.ការបង្កើនប្រសិទ្ធភាពការងាររដ្ឋបាល និងអភិបាលកិច្ចល្អ............ ៣៣

**សេចក្តីសន្និដ្ឋាន** ............ ៣៤

**អនុសាសន៍** ............ ៣៥

**គន្ថនិទ្ទេស**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាយើង ជាប្រទេសមួយទើបងើបចេញពីសង្គ្រាមជាច្រើនលើកច្រើនសារ ដែលបណ្តាលអោយខូចខាតនូវហេដ្ឋារចនាសម្ព័ន្ធជាច្រើន កត្តាទាំងអស់នេះហើយដែលធ្វើឱ្យប្រទេសយើងពុំមានការរីកចម្រើនដូចប្រទេសជិតខាង។ ដោយឡែកប្រទេសមួយអាចរីកចម្រើនទៅបានអាស្រ័យទៅលើ ធនធានមនុស្ស សេដ្ឋកិច្ច ជាពិសេសនោះគឺការគ្រប់គ្រងរដ្ឋបាលប្រកបដោយប្រសិទ្ធភាព។ យោងតាមការរៀបរាប់ខាងលើ ដូចយើងដឹងស្រាប់មកហើយថាការគ្រប់គ្រងរដ្ឋបាលក៏ជាចំណែកមួយដ៏សំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិអាស្រ័យដោយហេតុនេះហើយទើបបានជារាជរដ្ឋាភិបាលកម្ពុជាយើងមានការយកចិត្តទុកដាក់ជាខ្លាំង ទៅលើការគ្រប់គ្រងរដ្ឋបាលគ្រប់ជាន់ថ្នាក់អោយកាន់តែមានតម្លាភាព និងប្រកបដោយប្រសិទ្ធភាព ជាពិសេសនោះគឺការគ្រប់គ្រងរដ្ឋបាលថ្នាក់ឃុំ សង្កាត់តែម្តង ។ រដ្ឋបាលថ្នាក់ឃុំ សង្កាត់ គឺជាមូលដ្ឋានគ្រឹះរបស់រដ្ឋបាលទាំងមូល។ លើសពីនេះទៅទៀតក្រុមប្រឹក្សាឃុំ សង្កាត់ជាសេនាធិការរបស់រដ្ឋាភិបាល ហើយក៏ជារដ្ឋបាលមួយដែលនៅជិតប្រជាពលរដ្ឋបំផុត ដែលផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលសេវាសាធារណៈផ្សេងៗ ចំណេញថវិការ ពេលវេលា មិនតែប៉ុណ្ណោះធ្វើអោយប្រជាពលរដ្ឋមានភាពជិតស្និតជាមួយរដ្ឋាភិបាលរបស់ខ្លួនថែមទៀតផង ។ ក្រុមប្រឹក្សាឃុំ សង្កាត់គឺជាអ្នកដែលយល់ច្បាស់អំពីតម្រូវការរបស់ប្រជាពលរដ្ឋជាងគេ និងដឹងច្បាស់ថាគួរកសាងអ្វី ឬជួសជុលអ្វីនៅមូលដ្ឋានរបស់ខ្លួនដើម្បីបង្ករភាពងាយស្រួលជូនដល់ប្រជាពលរដ្ឋ។ លើសពីនេះទៅទៀត ប្រជាពលរដ្ឋក៏ទទួលបាននូវឪកាសក្នុងការបញ្ចេញមតិ និងសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្តទៅលើផលប្រយោជន៍ បញ្ហា និងផលប៉ះពាល់ផ្សេងៗនៅក្នុងមូលដ្ឋានរបស់ខ្លួនថែមទៀតផង។

ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មិនទាន់មានដំណើរការរលូននោះទេ ព្រោះជាក់ស្តែងនេះការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហាក់ដូចជាមិនទាន់ឆ្លើយតបទៅហ្នឹងអ្វីដែលរដ្ឋាភិបាលចង់បាននៅឡើយទេ ។ ហើយយើងក៏សង្កេតឃើញថាការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ នៅមានបញ្ហារាំងស្ទះជាច្រើន ចំពោះដំណើរការនៃការអនុវត្ត ។ ដោយយោងទៅតាមការរៀបរាប់ខាងលើនេះ រដ្ឋក៏បានបង្កើតឡើងនូវគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងអាជ្ញាធរមួយចំនួន ក្នុងគោលបំណងដើម្បីអោយការគ្រប់គ្រងរដ្ឋបាលគ្រប់ជាន់ថ្នាក់ដំណើរការប្រកបដោយប្រសិទ្ធិភាពស្របតាមតម្រូវការរបស់ប្រជាជន និងប្រទេសជាតិ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ជាអាជ្ញាធរវិមជ្ឈការដែលត្រូវបានទទួលស្គាល់ថាជាតំណាងរបស់រដ្ឋមួយដែលមានទីតាំងនៅតាមមូលដ្ឋាននានាទូទាំងប្រទេស។ ចាប់ពីឆ្នាំ ២០០១ មក ឃុំ សង្កាត់បានក្លាយខ្លួន

ជាភ្នាក់ងារវិមជ្ឈការដោយស្ថិតក្រោមការគ្រប់គ្រងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ឃុំ សង្កាត់មានស្វ័យភាពផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រងដោយខ្លួនឯង ប៉ុន្តែស្ថិតក្រោមការពិនិត្យដោយប្រយោលពីស្ថាប័នមានសមត្ថកិច្ចរបស់រដ្ឋលើកិច្ចការមួយចំនួនដែលចាំបាច់ តាមរយៈច្បាប់ និងលិខិតបទដ្ឋាននានា បានផ្តល់ឱ្យឃុំ សង្កាត់ មានសមត្ថកិច្ច និងតួនាទីយ៉ាងសំខាន់ក្នុងកិច្ចគ្រប់គ្រងរដ្ឋបាលដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវប្រធានបទស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នេះបានចោទជាបញ្ហាមួយចំនួនដូចជា៖

- តើក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទី និងភារកិច្ចអ្វីខ្លះ? តើឃុំ សង្កាត់បានអនុវត្តន៍នូវតួនាទីនិងភារកិច្ចរបស់ខ្លួនបានកម្រិតណា?
- តើដំណើរការនៃការគ្រប់គ្រងរដ្ឋបាលឃុំរកាពប្រាំប្រឈមនិងបញ្ហាអ្វីខ្លះ? ហើយថាតើក្រុមប្រឹក្សាឃុំរកាពប្រាំបានលើកយកនូវដំណោះស្រាយបែបណាក្នុងការដោះស្រាយនូវបញ្ហាទាំងនោះ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះ គឺមានគោលបំណងដើម្បីស្វែងយល់អោយកាន់តែច្បាស់អំពីការគ្រប់គ្រងរដ្ឋបាលរបស់ឃុំ សង្កាត់ និងដើម្បីបង្ហាញអំពីតថភាពជាក់ស្តែងនៃការផ្តល់សេវារបស់ក្រុមប្រឹក្សាឃុំ សង្កាត់ជូនដល់ប្រជាពលរដ្ឋ។ លើសពីនេះទៅទៀត ការសិក្សាស្រាវជ្រាវនេះគឺ ដើម្បីរួមចំណែកក្នុងការកែលម្អនូវចំណុចខ្វះខាត ដែលពាក់ព័ន្ធទៅនិងការគ្រប់គ្រងរដ្ឋបាលរបស់ឃុំ សង្កាត់ និងស្វែងយល់អំពី:

- សមត្ថភាពរបស់មន្ត្រីរាជការក្នុងការអនុវត្តការងារនៅក្នុងមូលដ្ឋានឃុំ សង្កាត់
- បញ្ហាប្រឈម និងដំណោះស្រាយរបស់ប្រឹក្សាឃុំរកាពប្រាំក្នុងការអនុវត្តការងារ

## ៤.ដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានដែនកំណត់ និងវិសាលភាពគ្រប់ដណ្តប់តែនៅលើសកម្មភាពនៃការអនុវត្តន៍ការងាររបស់រដ្ឋបាលឃុំរកាពប្រាំនៅឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧។ ដូច្នោះ ប្រធានបទស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំនេះយើងខ្ញុំសូមធ្វើការបកស្រាយទៅលើចំណុចមួយចំនួនទាក់ទងជាមួយនិងដំណើរការនៃការគ្រប់គ្រងរដ្ឋបាល បញ្ហាប្រឈម និងដំណោះស្រាយរបស់ឃុំរកាពប្រាំប៉ុណ្ណោះ។

## ៥.វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវទៅលើប្រធានបទស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នេះគឺគ្រាន់តែជាសារណាបញ្ចប់ការសិក្សាប៉ុណ្ណោះដូច្នេះយើងខ្ញុំស្រាវជ្រាវ និងដកស្រង់ទៅតាមឯកសារដែលមានស្រាប់ដូចជា

- ច្បាប់ លិខិតបទដ្ឋានគតិយុត្តិនានា
- សៀវភៅ របាយការណ៍ និងឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងប្រធានបទ
- និងស្រាវជ្រាវតាមបណ្តាញអ៊ីនធឺណេតជាដើម។

## ៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវលើប្រធានបទ «ការគ្រប់គ្រងរដ្ឋបាលឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ» ត្រូវបានរៀបចំដូចខាងក្រោមៈ

- សេចក្តីផ្តើម
- ជំពូកទី១៖ គឺបង្ហាញអំពី ការរៀបចំ និងការប្រព្រឹត្តទៅនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ដោយលើកយកនូវរាល់លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនានា មកធ្វើការបកស្រាយ។
- ជំពូកទី២៖ គឺបង្ហាញអំពី ដំណើរការនៃគ្រប់គ្រងរដ្ឋបាលឃុំរកាពប្រាំ ដោយធ្វើការសិក្សាអំពីស្ថានភាពភូមិសាស្ត្រ និងយុទ្ធសាស្ត្ររៀបចំផែនការគ្រប់គ្រងរដ្ឋបាលរបស់ឃុំរកាពប្រាំ ។
- ជំពូកទី៣៖ គឺលើកឡើងអំពី បញ្ហាប្រឈម និងដំណោះស្រាយ ដែលឃុំរកាពប្រាំបានជួបប្រទះ។
- សេចក្តីសន្និដ្ឋាន
- អនុសាសន៍
- គន្ថនិទ្ទេស
- ឧបសម្ព័ន្ធ

# ជំពូកទី ១

# ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលឃុំ សង្កាត់

## ១.១. ការរៀបចំរដ្ឋបាលឃុំ សង្កាត់

### ១.១.១. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន តាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ និងដោយសំងាត់។ ការបោះឆ្នោតនេះត្រូវបានធ្វើឡើងរៀងរាល់ប្រាំឆ្នាំម្តង ដោយការបោះឆ្នោតនៅគ្រប់ឃុំ សង្កាត់ទាំងអស់ត្រូវធ្វើឡើងនៅថ្ងៃអាទិត្យតែមួយថ្ងៃគត់[1]។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុវត្តន៍តាមប្រព័ន្ធសមាមាត្រដោយបែងចែកអាសនៈតាមមធ្យមភាគខ្ពស់បំផុត ក្រោមសមត្ថកិច្ចរៀបចំចាត់ចែង និងគ្រប់គ្រងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ដំណើរការប្រព្រឹត្តិទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងត្រូវរៀបចំតាមលំដាប់លំដោយដូចតទៅ៖

#### ក.ការចុះឈ្មោះបេក្ខជនបោះឆ្នោត

បេក្ខជនដែលមានបំណងឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណៈបក្សនយោបាយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ស្តីពីគណៈបក្សនយោបាយ[2]។ បន្ទាប់មកគណៈបក្សនយោបាយត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតដែលចុះហត្ថលេខាដោយប្រធានគណៈបក្សនយោបាយ ឬតំណាងដែលទទួលបានការផ្ទេរសិទ្ធិទៅជាគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតក្នុងរយៈពេលយ៉ាងតិច ៩០ ថ្ងៃមុនថ្ងៃបោះឆ្នោតដោយមានភ្ជាប់មកជាមួយនូវបញ្ជីរាយនាមបេក្ខជន ដែលមានចំនួនយ៉ាងហោចណាស់ស្មើនិងពីរដងនៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។ ប្រជាពលរដ្ឋទាំងពីរភេទដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាន និងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

[1] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់,ឆ្នាំ២០០៦,មាត្រា៣ថ្មី។

[2] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់,ឆ្នាំ២០០៦,មាត្រា៤៩ថ្មី។

ចំណែកបេក្ខជនត្រូវហាមមិនអោយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់រួមមានៈ

- សមាជិករដ្ឋសភា ព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិករាជរដ្ឋាភិបាល និងចៅក្រុម
- ប្រតិភូរាជរដ្ឋាភិបាល អភិបាល ឬអភិបាលរងរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ
- សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បុគ្គលិកបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិក្នុងមុខតំណែង
- ព្រះសង្ឃ ឬបុព្វសាសនា
- ស្មៀនឃុំ សង្កាត់

### ខ. ការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អោយបានយ៉ាងតិច ៩០ថ្ងៃមុនថ្ងៃបោះឆ្នោត [3]។ បន្ទាប់ពីរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់រួច គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់រយៈពេលនៃការត្រួតពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗមិនត្រូវតិចជាង ១៥ថ្ងៃឡើយ ។

ដើម្បីមានសិទ្ធិចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោមៈ

- មានសញ្ជាតិខ្មែរ
- មានអាយុ ១៨ឆ្នាំ ឡើងគិតមកដល់ថ្ងៃបោះឆ្នោត
- មិនស្ថិតក្នុងស្ថានភាពជាទណ្ឌិត ឬស្ថានភាពជាជនវិកលចរិកជាដើម[4] ។

### ១.១.២.រចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវមានរចនាសម្ព័ន្ធជាក់លាក់របស់ខ្លួនដោយផ្អែកតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

- ក្រុមប្រឹក្សា ឃុំ សង្កាត់ មានសមាជិក ៥,៧,៩ ឬ១១នាក់ផ្អែកតាមភូមិសាស្ត្រ និងចំនួនប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងឃុំ សង្កាត់។ ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

[3] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់,ឆ្នាំ២០០៦,មាត្រា៨៣។

[4] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់,ឆ្នាំ២០០៦,មាត្រា១៩ថ្មី។

- ក្រុមប្រឹក្សា ឃុំ សង្កាត់នីមួយៗមានប្រធាន០១រូប ដែលហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាមេឃុំ ចៅសង្កាត់ ។
- ឃុំ សង្កាត់នីមួយៗមានមេឃុំ ចៅសង្កាត់ម្នាក់។ ស្ត្រី និងបុរសអាចត្រូវបានជ្រើសរើសអោយធ្វើជាមេឃុំ ចៅសង្កាត់ដោយផ្អែកតាមលទ្ធផលនៃការបោះឆ្នោត។
- មេឃុំ ចៅសង្កាត់មានជំនួយការ០២រូប គឺជំទប់ទីមួយ ឬចៅសង្កាត់រងទី០១ និងជំទប់ទី០២ ឬចៅសង្កាត់រងទី០២[5] ។
- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសអោយមានមេភូមិម្នាក់សម្រាប់ភូមិនីមួយៗក្នុងឃុំ សង្កាត់របស់ខ្លួនដោយអនុវត្តន៍តាមសេចក្តីណែនាំលេខ ០០៤ស.ណ.ន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃស្តីពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែងការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ចរបៀបរបបធ្វើការងាររបស់មេភូមិ។ មេភូមិ គឺជាតំណាងអោយប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់។ មេភូមិត្រូវមានជំនួយការរបស់ខ្លួន០២រូបម្នាក់ជាអនុប្រធានភូមិ និងម្នាក់ទៀតជាសមាជិកភូមិ។
- មេឃុំ ចៅសង្កាត់អាចចាត់តាំងបង្កើតគណៈកម្មាធិការនានាបានតាមការចាំបាច់ ។ គណៈកម្មាធិការនីមួយៗមានសមាជិកយ៉ាងតិច០៣នាក់ ដើម្បីផ្តល់យោបល់ និងជួយការងារដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់អំពីបញ្ហាជាក់លាក់ណាមួយ។ គណៈកម្មាធិការនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់អោយធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អោយធ្វើជាប្រធានក៏បាន[6] ។
- ឃុំ សង្កាត់នីមួយៗមានស្មៀនមួយរូបដែលត្រូវបានតែងតាំង និងបម្រើការងារនៅក្នុងក្របខណ្ឌរដ្ឋបាលក្រសួងមហាផ្ទៃ [7]។ ស្មៀនឃុំ សង្កាត់ទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងការបំពេញមុខងាររបស់ខ្លួន ស្មៀនឃុំ សង្កាត់ត្រូវតែអព្យាក្រឹត្យមិនលម្អៀង ហើយត្រូវប្រកាន់ឥរិយាបថអោយបានស្មើៗគ្នាចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាគ្រប់រូបដោយមិនប្រកាន់និន្នាការនយោបាយ និងចំពោះគណៈកម្មាធិការនានា។

[5] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា២៦។

[6] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា២៧។

[7] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា២៨។

### ១.១.៣.សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់

ដោយផ្អែកលើលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ សមាសភាពនៃក្រុមប្រឹក្សាឃុំមានរាយនាមដូចតទៅៈ

- លោក អ៊ុំ ជា ជាប្រធានក្រុមប្រឹក្សាឃុំ (មេឃុំ)
- លោក អ៊ុំ ដារ៉ូត ជាសមាជិកក្រុមប្រឹក្សាឃុំ (ជំទប់ទី១)
- លោក ខឹម សារិន ជាសមាជិកក្រុមប្រឹក្សាឃុំ (ជំទប់ទី២)
- លោកស្រី អ៊ិត គីមហុង ជាសមាជិកក្រុមប្រឹក្សាឃុំ
- លោក ចេន មុនី ជាសមាជិកក្រុមប្រឹក្សាឃុំ
- លោក អេល តូរ៉ម៉ាន ជាសមាជិកក្រុមប្រឹក្សាឃុំ
- លោក វ៉ា ម៉ាប់ ជាសមាជិកក្រុមប្រឹក្សាឃុំ
- លោក ម៉ាត់ អាលី ជាសមាជិកក្រុមប្រឹក្សាឃុំ
- លោក គឹម ណាវ៉ា ជាសមាជិកក្រុមប្រឹក្សាឃុំ
- លោក គឹម បូផា ជាសមាជិកក្រុមប្រឹក្សាឃុំ
- លោក ធី សំបូរ ជាសមាជិកក្រុមប្រឹក្សាឃុំ

### ១.១.៤.តួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

ដើម្បីជំរុញអោយមានប្រសិទ្ធភាពខ្ពស់នូវការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អោយកាន់តែប្រសើរឡើង រដ្ឋាភិបាលក៏បានធ្វើការកំណត់ឪ្យកាន់តែច្បាស់នូវតួនាទី មុខងារ និងអំណាចក្នុងការអនុវត្តការងាររបស់រដ្ឋបាលឃុំ សង្កាត់។

#### ក. តួនាទី និងមុខងាររបស់រដ្ឋបាលឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់មានមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍមូលដ្ឋាន ពង្រឹងសណ្ដាប់ធ្នាប់ និងការពារសុខសុវត្ថិភាពជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន។ លើសពីនេះទៅទៀតក្រុមប្រឹក្សាឃុំ សង្កាត់ក៏មានតួនាទីជាភ្នាក់ងាររដ្ឋដ៏ល្អ ដែលត្រូវគោរព និងប្រតិបត្តិតាមលិខិតបទដ្ឋានគតិយុត្តនានាដែលនៅជាធរមានផងដែរ។ រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អដោយចាត់ចែងប្រើប្រាស់ធនធាននានាប្រកបដោយចីរភាព សម្រាប់បំពេញសេចក្ដីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ [៨]។ រដ្ឋបាលឃុំ សង្កាត់មានតួនាទីជាភ្នាក់ងាររដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ [៩]។

[៨] ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៤១។

**តួនាទីបម្រើកិច្ចការមូលដ្ឋាន** រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច ធានារក្សាសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ។ ហើយរៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវអោយកិច្ចការទាំងនោះដំណើរការបានល្អ។ លើកទឹកចិត្តអោយមានការបង្កើតផាសុកភាព និងសុខុមាភាពរបស់ប្រជាពលរដ្ឋ ជំរុញកិច្ចអភិវឌ្ឍន៍ សេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការពារថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ និងសម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីអោយមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក។ បំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ[10]។

**តួនាទីជាភ្នាក់ងារតំណាងរដ្ឋ** រដ្ឋបាលឃុំ សង្កាត់ជាភ្នាក់ងារមួយតំណាងរដ្ឋដែលមានភារកិច្ចអនុវត្តន៍ទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានដែលពាក់ព័ន្ធ។ ក្នុងករណីនេះអាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាពនិងផ្តត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកាសម្រាប់អនុវត្តន៍។ ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ [11]។

### ខ. អំណាចរបស់រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ រដ្ឋបាលឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ [12]។

**អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់** ត្រូវធ្វើឡើងតាមរយៈដីការឃុំ សង្កាត់ តាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ សម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់អោយ។ ដីកាឃុំ សង្កាត់ មានប្រសិទ្ធភាពអនុវត្តន៍តែនៅក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ ។ ដីកាឃុំ សង្កាត់ មិនត្រូវផ្ទុយពីសន្ធិសញ្ញា អនុសញ្ញាអន្តជាតិដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ស្មារតីរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធឡើយ [13] ។ បើដីការណាមួយដែលផ្ទុយពីបទដ្ឋានគតិយុត្តខាងលើនេះ ដីកានោះនឹងត្រូវចាត់ទុកជាមោឃៈដាច់ខាត ។

---

[9] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៤២។

[10] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៤៣។

[11] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៤៥។

[12] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៤៨។

[13] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០១១,មាត្រា៤៩។

**អំណាចប្រតិបត្តិរបស់ឃុំ សង្កាត់** មានន័យថារដ្ឋបាលឃុំ សង្កាត់ មានសិទ្ធអនុវត្តន៍សេចក្តីសម្រេចរបស់ខ្លួននៅក្នុងក្របខណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។ អំណាចប្រតិបត្តិនេះត្រូវបានធ្វើប្រតិភូកម្មអោយទៅមេឃុំ ចៅសង្កាត់ជាអ្នកអនុវត្តន៍ក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ របស់ខ្លួន។

**គ. ព្រំដែននៃអំណាច**

រដ្ឋបាលឃុំ សង្កាត់អាចធ្វើសកម្មភាពបានតែនៅក្នុងក្របខណ្ឌអំណាច តួនាទី និងមុខងារ ដែលច្បាប់បានប្រគល់អោយប៉ុណ្ណោះ។ ពោលគឺ រដ្ឋបាលឃុំ សង្កាត់ មិនអាចធ្វើសកម្មភាពណាមួយដែលផ្ទុយនិងគោលការណ៍ និងបទបញ្ញត្តិដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ ច្បាប់ ព្រះរាជក្រឹត្យ ប្រកាស លិខិតបទដ្ឋាននានាឡើយ។

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសម្រេចលើវិស័យះ

- ព្រៃឈើប្រៃសណីយ៍ និងទូរគមនាគមន៍
- ការពារជាតិ
- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ និង
- វិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ពន្ធ័[14]។

**១.១.៥.តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់**

ជាទូទៅរដ្ឋបាលឃុំ សង្កាត់មានតួនាទី និងការទទួលខុសត្រូវដាច់ដោយឡែកពីគ្នាទៅតាមមុខតំណែងរបស់ខ្លួន។

**ក. ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មានតួនាទីដូចជា ជាអធិបតីក្នុងសម័យក្រុមប្រឹក្សាឃុំនៅពេលមានការប្រជុំ ។ មិនតែប៉ុណ្ណោះ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ធានាអោយសម័យប្រជុំក្រុមប្រឹក្សាឃុំរបស់ខ្លួនដំណើរការបានត្រឹមត្រូវតាមវិធាន និងបទបញ្ជាដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ និងរក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំរបស់ក្រុមប្រឹក្សាឃុំ[15]។

---

[14] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០០១,មាត្រា៤៥។

[15] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០០១,មាត្រា១៣។

ជាមួយគ្នានេះផងដែរ ក្រុមប្រឹក្សាឃុំ សង្កាត់ក៏អាចធ្វើប្រតិភូកម្មអំណាចដល់មេឃុំ និងចៅសង្កាត់ផងដែរ [16]។ លើសពីនេះទៅទៀតប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ធានាអោយមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំយ៉ាងតិចមួយដងក្នុងមួយខែជាដាច់ខាត ។ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ក៏ត្រូវរៀបចំអនុវត្តន៍ផែនការអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន ដោយចាត់វិធានការដូចជា វាយតម្លៃជាអាទិភាព និងសកម្មភាពអភិវឌ្ឍន៍ប្រមូលផ្តុំសេចក្តីត្រូវការ និងកំណត់អាទិភាពនៃសេចក្តីត្រូវការទាំងនោះអោយបានជាក់លាក់ដោយផ្អែកលើធនធានដែលមានស្រាប់ រៀបចំកម្មវិធីអភិវឌ្ឍន៍ទៅក្នុងគម្រោងថវិកាឃុំ ផ្តល់សេវា និងអភិវឌ្ឍន៍តាមថវិកាដែលឃុំមាន ហើយត្រួតពិនិត្យនិងវាយតម្លៃចំពោះលទ្ធផលក្រោយការអនុវត្ត ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ពីការអភិវឌ្ឍជូនប្រជាពលរដ្ឋរបស់ខ្លួន និងធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហើយតម្កល់ទុកជាសាធារណៈ ចម្លងចែកជូនអង្គការ សមាគមន៍ និងសធារណៈជនសំខាន់ដោយគិតត្រឹមថ្លៃដើម [17]។

### ខ.មេឃុំ ឬចៅសង្កាត់

ចំពោះមេឃុំ ចៅសង្កាត់វិញមានតួនាទីដូចជា អនុវត្តន៍សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ ការធ្វើសេចក្តីរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួនអោយបានយ៉ាងតិចមួយខែម្តង ។ ហើយក៏នៅមានការអនុវត្តបទបញ្ញត្តិ និងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ និងការផ្តល់យោបល់ផ្សេងៗទៀត និងជួយដល់ក្រុមប្រឹក្សាឃុំក្នុងការរៀបចំផែនការហិរញ្ញវត្ថុ និងចាត់ចែងអនុវត្តន៍តួនាទី មុខងារ និងសិទ្ធអំណាចរបស់ក្រុមប្រឹក្សាឃុំព្រមទាំងកិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាឃុំបានប្រគល់ឱ្យ [18]។ ជាងនេះទៅទៀត មេឃុំក៏ជាអ្នកអនុវត្តន៍តាមគោលនយោបាយរបស់រដ្ឋ និងទទួលការធ្វើប្រតិភូកម្មអំណាចពីក្រុមប្រឹក្សា ឃុំ សង្កាត់ ហើយអ្វីដែលសំខាន់នោះមេឃុំក៏ជាមន្ត្រីអគ្រានុកូលដ្ឋានផងដែរ ។

### គ.ជំទប់ឃុំ ឬចៅសង្កាត់រង

ជំទប់ឃុំ ឬចៅសង្កាត់រងមានតួនាទីដូចតទៅ ជំទប់ឃុំជាជំនួយការរបស់មេឃុំ[19] ហើយអនុវត្តន៍ភារកិច្ចដែលមេឃុំប្រគល់អោយ និងជាជំនួយការមេឃុំទៅតាមឋានានុក្រមនៃជំទប់នៅពេលមេឃុំអវត្តមាន ។ ហើយនៅក្នុងនោះផងដែរជំទប់ទីមួយជាជំនួយការមេឃុំលើកិច្ចការសេដ្ឋកិច្ចហិរញ្ញវត្ថុ រីឯជំទប់ទីពីរជាជំនួយការមេឃុំលើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈ និង សណ្តាប់ធ្នាប់សាធារណៈ ។

---

[16] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០០១,មាត្រា៥២។

[17] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១,មាត្រា៧០។

[18] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០០១,មាត្រា៣៩។

[19] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០០១,មាត្រា២៩។

**ឃ.គណៈកម្មាធិការនានា**

គណៈកម្មាធិការនានារបស់ឃុំ សង្កាត់ ត្រូវបានបង្កើតឡើងក្នុងករណីដែលឃុំមានការចាំបាច់ក្នុងការអនុវត្តគោលនយោបាយរបស់ឃុំ ហើយគណៈកម្មាធិការនានាមានតួនាទីផ្តល់យោបល់ និងជួយការងាជាក់លាក់ណាមួយរបស់ក្រុមប្រឹក្សាឃុំ ដូចជាការកសាងផែនការ និងថវិការឃុំ រាយការណ៍អំពីការអភិវឌ្ឍប្រចាំខែរបស់ខ្លួន និង ផ្តល់យោបល់ពីវិធានការដែលត្រូវអនុវត្តន៍ពាក់ពន្ធ័ជាមួយ និងការងារ ។

**ខ. ស្មៀនឃុំ**

នៅគ្រប់ឃុំ សង្កាត់ទាំងអស់មិនមែនត្រឹមតែឃុំរកាពប្រាំប៉ុណ្ណោះទេត្រូវមានបុគ្គលិករដ្ឋបាលក្រសួងមហាផ្ទៃ ហើយជាមន្រ្តីមុខងារសាធារណៈតែងតាំងដោយប្រកាសរបស់រដ្ឋមន្រ្តីក្រសួងមហាផ្ទៃ ហើយអាចផ្លាស់ប្តូរតាមសំណើររបស់មេឃុំ ចៅសង្កាត់ ផ្អែកតាមការសម្រេចពីក្រុមប្រឹក្សាឃុំ សង្កាត់ នោះរដ្ឋមន្រ្តីក្រសួងមហាផ្ទៃនិងចេញប្រកាសផ្លាស់ប្តូរ [20]។ ហើយស្មៀនឃុំជាមន្រ្តីក្របខណ្ឌរដ្ឋបាលរបស់ក្រសួងមហាផ្ទៃដែលចាត់អោយទៅបម្រើការងារជាជំនួយការរដ្ឋបាលឃុំ សង្កាត់ ដែលមានភារកិច្ចធានានិរន្តភាពកិច្ចការរដ្ឋបាលឃុំ សង្កាត់។ ដូច្នេះស្មៀនឃុំមានចៅហ្វាយពីរ គឺមន្រ្តីក្រសួងមហាផ្ទៃ និងក្រុមប្រឹក្សាឃុំ ។

**ច. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់**

សមាជិកក្រុមប្រឹក្សឃុំមានតួនាទីដូចជា ត្រូវធ្វើការធានាថាក្រុមប្រឹក្សាឃុំប្រើប្រាស់អំណាច តួនាទី និងភារកិច្ចដូចមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានដែលពាក់ព័ន្ធ ហើយសមាជិកក្រុមប្រឹក្សាឃុំក៏ត្រូវចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ និងធ្វើសហប្រតិបត្តិការជាមួយនិងប្រជាពលរដ្ឋផងដែរ ។

**ឆ. មេភូមិ**

មេភូមិមានតួរនាទីទទួលខុសត្រូវរួមក្នុងភូមិរបស់ខ្លួន ហើយជាតំណាងអោយប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ ។ បង្កើតការពិគ្រោះយោបល់ទទួលការណែនាំ និងកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំរបស់ខ្លួន។ មិនតែប៉ុណ្ណោះ មេភូមិមានភារកិច្ចអនុវត្តន៍កិច្ចការដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ប្រគល់អោយដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងភូមិ ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ភូមិរបស់ខ្លួន និងធ្វើការស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែង និងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន [21]។

[20] អនុបណ្ឌិត ហៀង សាង,នីតិរដ្ឋបាលទូទៅ,ឆ្នាំ២០១១,ទំព័រ១២២។

[21] សៀវភៅក្រសួងមហាផ្ទៃ,ការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់តាមបែបវិមជ្ឈការ,ឆ្នាំ២០០៧,ទំព័រ២១។

ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ឃុំ ដើម្បីផ្តល់យោបល់អំពីកិច្ចការនៅក្នុងភូមិរបស់ខ្លួនដូចជា ផ្តល់យោបល់ដល់គណៈកម្មាធិការភូមិអំពីតម្រូវការ និងផលប្រយោជន៍របស់ភូមិ ផ្តល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិអំពីរបៀបបង្កើន និងកសាងសមត្ថភាព និងធនធានរបស់ភូមិ ផ្តល់យោបល់ដល់គណៈកម្មាធិការកសាងផែនការ និងថវិកាភូមិអំពី (តម្រូវការ និងអាទិភាពរបស់ភូមិដើម្បីបញ្ចូលក្នុងផែនការអភិវឌ្ឍឃុំក្នុងភូមិរបស់ខ្លួន ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តផែនការអភិឌ្ឍឃុំ ត្រូវធ្វើសេចក្តីរាយការណ៍រាល់បញ្ហាដែលពាក់ព័ន្ធ និងភូមិរបស់ខ្លួនដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ) ។ ការចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ ត្រូវធានាផ្តល់ពត៌មានជាឯកសារសាធារណៈដែលពាក់ព័ន្ធទៅនិងភូមិជូនប្រជាពលរដ្ឋរបស់ខ្លួនឲ្យបានដឹង។ ឯកសារទាំងនោះរួមមានពត៌មានស្តីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ ផែនការអភិវឌ្ឍន៍ឃុំ និងថវិការឃុំ ហើយត្រូវទទួលខុសត្រូវអនុវត្តន៍កិច្ចការដែលបានប្រគល់ឲ្យដោយក្រុមប្រឹក្សាឃុំរបស់ខ្លួន ។

## ១.២.កិច្ចការរដ្ឋបាលរបស់ឃុំ សង្កាត់

កិច្ចរដ្ឋបាលរបស់ឃុំ សង្កាត់មានដូចជា លិខិតបទដ្ឋានគតិយុត្ត លិខិតរដ្ឋបាល ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងឯកសារ ការគ្រប់គ្រងសម្ភារៈបរិក្ខា និងការរៀបចំកិច្ចប្រជុំជាដើម។

### ១.២.១.លិខិតបទដ្ឋានគតិយុត្តឃុំ សង្កាត់

លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់ គឺជាលិខិតដែលកំណត់នូវវិធាន បទបញ្ញត្តិ បទបញ្ជា ឬគោលការណ៍នានាសម្រាប់ការគ្រប់គ្រង ការតែងតាំង ការបង្កើតឡើងនូវយន្តការ និងការណែនាំអនុវត្តន៍កិច្ចការនានា ។ ប្រភេទលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់មានដូចជា៖

#### ក.ដីកាឃុំ សង្កាត់

ដីកាឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានគតិយុត្តដែលកំណត់នូវបទបញ្ញត្តិទាំងឡាយដែលរដ្ឋបាលឃុំសង្កាត់បង្កើតឡើង សំដៅបម្រើផលប្រយោជន៍ប្រជាពលរដ្ឋទូទៅក្នុងឃុំ សង្កាត់ដោយស្មើភាព មិនរើសអើង និងសម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តន៍ក្នុងរង្វង់ដែនដីរបស់ខ្លួន ។

ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនិងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋឡើយ ។ ដីកាឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ។

### ខ. សេចក្តីសម្រេចឃុំ សង្កាត់

សេចក្តីសម្រេចឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានគតិយុត្តដែលបង្កើតឡើង ដើម្បីអនុវត្តន៍ដីការបស់ខ្លួន ឬលិខិតបទដ្ឋាននានារបស់រដ្ឋ ឬថែងអំពីការបង្កើត ការតែងតាំង ការរៀបចំ ឬការគ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តន៍ក្នុងរង្វង់ដែនដីរបស់ខ្លួន ។

សេចក្តីសម្រេចមានលក្ខណៈប្រហាក់ប្រហែល និងដីកាឃុំ សង្កាត់ដែរប៉ុន្តែមានឋានុក្រមទាបជាងដីកា និងខ្ពស់ជាងលិខិតរដ្ឋបាលសាមញ្ញធម្មតាផ្សេងៗទៀតក្នុងឃុំ សង្កាត់ ។ សេចក្តីសម្រេចឃុំ សង្កាត់មិនត្រូវផ្ទុយនិងច្បាប់ ឬលិខិតបទដ្ឋាននានារបស់រដ្ឋ និងដីការបស់ខ្លួនឡើយ ។ សេចក្តីសម្រេចឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។

ក្នុងករណីប្រធានសក្តិ និងបន្ទាន់បំផុតដែលមិនអាចកោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បាន មេឃុំ ចៅសង្កាត់អាចចេញសេចក្តីសម្រេច ដើម្បីដោះស្រាយស្ថានភាពបន្ទាន់នោះ ។ សេចក្តីសម្រេចនេះ និងត្រូវដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់នៅកិច្ចប្រជុំបន្ទាប់ ដើម្បីពិនិត្យឡើងវិញអំពីភាពត្រឹមត្រូវតាមច្បាប់ ។

### ១.២.២. លិខិតរដ្ឋបាលឃុំ សង្កាត់

លិខិតរដ្ឋបាល គឺជាលិខិតដែលរៀបចំតាក់តែងឡើងជាលាយលក្ខណ៍អក្សរសម្រាប់ជាមធ្យោបាយទំនាក់ទំនងផ្លូវការរបស់រដ្ឋបាលឃុំ សង្កាត់ជាមួយស្ថាប័ន អង្គភាព និងបុគ្គលនានា ក្នុងគោលបំណងជូនពត៌មានណែនាំ អញ្ជើញ រាយការណ៍ ផ្សព្វផ្សាយ ឆ្លើយតប ឬចាត់តាំង បុគ្គលណាមួយអោយទៅបំពេញបេសកម្ម ។

លិខិតរដ្ឋបាលឃុំ សង្កាត់ដែលប្រើប្រាស់ជាផ្លូវការរួមមាន លិខិតស្នើ លិខិតជូនដំណឹង ឬសេចក្តីជូនដំណឹង លិខិតអញ្ជើញ លិខិតបញ្ជាបេសកម្ម របាយការណ៍ កំណត់ហេតុ លិខិតផ្ទេរសិទ្ធិ និងដីការអម ។

- **លិខិតស្នើ៖** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើង ដើម្បីបង្ហាញពីគោលបំណង និងមូលហេតុនៃតម្រូវការជាក់លាក់ណាមួយរបស់ខ្លួនថ្លែងទៅកាន់រូបវន្តបុគ្គល នីតិបុគ្គលសាធារណៈ ឯកជន ក្រសួង ស្ថាប័ន អង្គការ ឬសង្គមស៊ីវិលដែលមានសិទ្ធិអំណាចសម្រេច ឬដោះស្រាយចំពោះការស្នើសុំនោះ ។
- **សេចក្តីជូនដំណឹង៖** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើការទំនាក់ទំនងជាមួយបុគ្គល ប្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលមានខ្លឹមសារជាការឆ្លើយបំភ្លឺចំពោះបញ្ហា ឬជាការ

ឆ្លើយតបចំពោះសំណើ ឬជាការជូនដំណឹងអោយសាធារណៈជនបានដឹងនូវពត៌មានទាំងឡាយដែលឃុំ សង្កាត់ត្រូវការផ្សព្វផ្សាយ ។

- **លិខិតអញ្ជើញ៖** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើការអញ្ជើញបុគ្គល ឬតំណាងក្រសួងស្ថាប័ន អង្គការសង្គមស៊ីវិលអោយចូលរួមក្នុងសកម្មភាពរបស់ឃុំ សង្កាត់ចំពោះកិច្ចការដែលពាក់ព័ន្ធទៅនិងបុគ្គល ឬអង្គភាពទាំងនោះដោយមានបញ្ជាក់ឈ្មោះ និងឋានៈ (អ្នកដែលត្រូវអញ្ជើញ) ទីកន្លែងប្រជុំ ឬប្រារព្ធពិធី កាលបរិច្ឆេទកម្មវិធី ឬរបៀបវារៈប្រជុំ (និងអាចមានឯកសារដែលពាក់ព័ន្ធនិងការប្រជុំភ្ជាប់ជាមួយ) ។
- **លិខិតបញ្ជាបេសកម្ម៖** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីចាត់តាំងមន្ត្រី បុគ្គលិកឃុំ សង្កាត់អោយចូលរួមក្នុងសកម្មភាពនានានៅក្រៅឃុំ សង្កាត់ ។ លិខិតនេះមានភ្ជាប់ជាមួយនូវទិដ្ឋាការធ្វើដំណើរ។ ទិដ្ឋាការធ្វើដំណើរ គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់អោយអ្នកដែលមានភារកិច្ចទៅបំពេញបេសកកម្ម យកទៅចុះទិដ្ឋាការនូវទីកន្លែង ការបរិច្ឆេទ មធ្យោបាយធ្វើដំណើរ និងហត្ថលេខារបស់អង្គភាពមានសមត្ថកិច្ចដែលបានអនុញ្ញាត និងអង្គភាពដែលបានទទួលដឹងលឺអំពីការចេញដំណើរ និងការមកដល់ពីដំណាក់មួយមកដំណាក់មួយទៀត ។ នៅពេលត្រឡប់មកវិញ ត្រូវធ្វើរបាយការណ៍ ឬរាយការណ៍ជូនមេឃុំ ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់អោយបានជ្រាបអំពីលទ្ធផល ឬបញ្ហាសំខាន់ៗដែលខ្លួនបានទៅចូលរួម ។
- **របាយការណ៍៖** គឺជាសេចក្ដីរាយការអំពីសកម្មភាព ដំណើរការ និងលទ្ធផលការងាររបស់ឃុំ សង្កាត់ ឬបុគ្គលិកណាម្នាក់ ឬមួយក្រុមដែលរដ្ឋបាលឃុំ សង្កាត់បានបំពេញ ឬឃុំ សង្កាត់បានចាត់តាំងអោយទៅបំពេញ ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ និងអង្គភាពពាក់ព័ន្ធ ។
- **កំណត់ហេតុ៖** គឺជាការកត់ត្រាស្រង់យកមតិយោបល់សេចក្ដីសម្រេច និងការឯកភាពលើសកម្មភាព ដែលត្រូវអនុវត្តន៍ពីគ្រប់សមាជិកអង្គប្រជុំ និងការសម្រេចរបស់អង្គប្រជុំ ឬជាការកត់ត្រារាល់ហេតុការណ៍ណាមួយដែលបានកើតឡើងជាក់ស្តែង ដើម្បីរក្សាទុកជាសក្ខីភាពនៅពេលដែលមានតម្រូវការ ។
- **លិខិតផ្ទេរសិទ្ធិ៖** គឺជាលិខិតរបស់មេឃុំ ចៅសង្កាត់ប្រកាសជាលាយលក្ខណ៍អក្សរប្រគល់សិទ្ធិអោយជំទប់ ចៅសង្កាត់រងតាមឋានានុក្រមដើម្បីធ្វើជាមេឃុំ ចៅសង្កាត់ស្ដីទីក្នុងអំឡុងពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន ។
- **ដីកាអម៖** គឺជាឯកសាររដ្ឋបាលដែលឃុំ សង្កាត់រៀបចំឡើង ផ្ញើរអមភ្ជាប់ជាមួយសំណុំលិខិតដែលត្រូវផ្ញើចេញទៅអោយអង្គភាព ក្រសួង ស្ថាប័នណាមួយ ដោយមានកត់ត្រាឈ្មោះ និង

ចំនួនលិខិត(ឯកសារ)លើដីកាអមនោះ ។ ឃុំ សង្កាត់ប្រើដីកាអម ដើម្បីចៀសវាងការបាត់បង់ឯកសារដែលរដ្ឋបាលឃុំ សង្កាត់ផ្ញើចេញ ។

### ១.២.៣.ការគ្រប់គ្រងបុគ្គលិករបស់ឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់មានបុគ្គលិកពីរប្រភេទ គឺស្មៀនដែលរដ្ឋាភិបាលបានបញ្ជូនអោយមកធ្វើការក្នុងឃុំ និងបុគ្គលិករបស់ឃុំផ្ទាល់ ។ ស្មៀនឃុំគ្មានសិទ្ធិគ្រប់គ្រង់លើបុគ្គលិកផ្ទាល់របស់ក្រុមប្រឹក្សាឃុំទេ ។ ករណីដែលក្រុមប្រឹក្សាឃុំ និងស្មៀនមានភាពមិនចុះសម្រុងគ្នា ក្រុមប្រឹក្សាឃុំមានសិទ្ធិស្នើសុំប្តូរស្មៀន ហើយក្រសួងមហាផ្ទៃត្រូវតែឆ្លើយតបជាវិជ្ជមានចំពោះការស្នើរសុំនេះ ។ ដូច្នេះការចាត់ចែងរបៀបនេះនាំអោយមានតុល្យភាពអំណាចរវាងក្រុមប្រឹក្សា និងស្មៀនឃុំ ក្នុងការងាររដ្ឋបាលប្រចាំថ្ងៃ និងការធ្វើសេចក្តីសម្រេចនានា ។

ក្របខណ្ឌច្បាប់មិនបានចែងលំអិត អំពីប្រព័ន្ធគ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំទេ ច្បាប់គ្រាន់តែបញ្ជាក់ថាក្រុមប្រឹក្សាអាចជួយបុគ្គលិករបស់ខ្លួនផ្ទាល់ ស្ថិតក្រោមការចាត់ចែងសព្វថ្ងៃនេះក្រុមប្រឹក្សាឃុំសង្កាត់អាចជួយគណនេយ្យករអោយជួយគ្រប់គ្រងចំណូលដែលឃុំរកបាន។

### ១.២.៤.ការគ្រប់គ្រងឯកសារ

ការគ្រប់គ្រងឯកសារ គឺជាការរៀបចំទុកដាក់ និងថែរក្សាឯកសារទាំងឡាយតាមប្រព័ន្ធមួយដែលមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព ។

ការគ្រប់គ្រងឯកសាររបស់ឃុំ សង្កាត់ផ្តល់ផលប្រយោជន៍មួយចំនួនដូចជាៈ

- បង្កលក្ខណៈងាយស្រួលក្នុងការស្វែងរកពត៌មាន និងទិន្នន័យសម្រាប់ដឹកនាំនៅក្នុងការពិភាក្សា និងការធ្វើសេចក្តីសម្រេច
- ជួយបន្តនិរន្តរភាពពត៌មាននៅពេលមានអ្នកមកកាន់ការងារថ្មី និងអ្នកផ្លាស់ចេញ
- ផ្តល់នូវភស្តុតាងជាក់លាក់ពីកិច្ចការ ឬព្រឹត្តការណ៍ដែលកើតរួចមកហើយ
- បង្កើនប្រសិទ្ធិភាព និងសន្សំពេលវេលាដល់ការងាររដ្ឋបាលឃុំ សង្កាត់ ។

### ១.២.៥.ការគ្រប់គ្រងសម្ភារបរិក្ខាឃុំ សង្កាត់

គ្រប់សម្ភារបរិក្ខារបស់ឃុំ សង្កាត់ត្រូវចុះបញ្ជីអោយបានត្រឹមត្រូវ។ ហើយ បញ្ជីគ្រប់គ្រងបរិក្ខានេះត្រូវរក្សាទុកអោយបានល្អ ប្រកបដោយសុវត្ថិភាព និងធ្វើបច្ចុប្បន្នជាប្រចាំ ។ គ្រប់សម្ភារបរិក្ខារបស់ឃុំសង្កាត់ដែលកាត់ចេញពីបញ្ជីត្រូវធ្វើឡើងស្របតាមនីតិវិធី និងត្រូវសម្រេចដោយកិច្ចប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ ។

### ១.២.៦.ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់

**ក. លិខិតអញ្ជើញ**

មេឃុំ ចៅសង្កាត់ត្រូវតែធានាថា លិខិតអញ្ជើញត្រូវបានរៀបចំ និងផ្ញើជូនដល់អ្នកដែលត្រូវបានចូលរួមប្រជុំគ្រប់គ្នាទាំងអស់អោយបានមុនពេលប្រជុំ។

លិខិតអញ្ជើញត្រូវតែបញ្ជាក់អោយបានច្បាស់លាស់អំពី ពេលវេលា ទីកន្លែង និងបញ្ហាសំខាន់ដែលត្រូវពិភាក្សា ឬជំរាបនៅពេលប្រជុំ និងឯកសារពាក់ព័ន្ធដែលភ្ជាប់ជាមួយលិខិតអញ្ជើញ។

**ខ. ការបង្កើតរបៀបវារៈប្រជុំ**

គ្រប់ការប្រជុំទាំងអស់ត្រូវមានរបៀបវារៈ ហើយត្រូវផ្ញើរជូនដល់អ្នកចូលរួមជាមុន។ ជាការប្រសើរអ្នកចូលរួមគួរមានឪកាសចូលរួមក្នុងការរៀបចំរបៀបវារៈ។

ចំណុចមួយចំនួនដែលយើងគួរលើកមកក្នុងការបង្កើតរបៀបវារៈរួមមានដូចជា

- ការងារដែលត្រូវពិភាក្សា និងសម្រេច
- ពត៌មានដែលត្រូវជំរាប
- ពេលវេលាសម្រាប់កិច្ចប្រជុំ

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ច្រើនជាងមួយភាគបីអាចបន្ថែមប្រធានបទផ្សេងទៀតដែលសិតនៅក្នុងអំណាច និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ។

ចំនួនប្រជាពលរដ្ឋដែលអាចដាក់ស្នើបញ្ចូលបញ្ហាទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បានមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

**គ. ការផ្សព្វផ្សាយអំពីកិច្ចប្រជុំដល់សាធារណៈជន**

កាលបរិច្ឆេទ និងទីកន្លែងនៃកិច្ចប្រជុំ ត្រូវផ្សព្វផ្សាយជាសាធារណៈដោយបិតផ្សាយនៅលើក្តាខៀនពត៌មានឃុំ សង្កាត់ និងនៅកន្លែងសាធារណៈក្នុងភូមិទាំងអស់ និងមធ្យោបាយផ្សព្វផ្សាយសមស្របដែលមាននៅមូលដ្ឋាន ។

# ជំពូកទី ២

# ដំណើរការនៃការគ្រប់គ្រងរដ្ឋបាលឃុំកាពប្រាំ

## ២.១.ស្ថានភាពភូមិសាស្ត្រ

ឃុំកាពព្រាំ ជាឃុំមួយក្នុងចំណោមឃុំទាំងដប់បួនស្ថិតនៅក្នុងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំដែលមាន ព្រំប្រទល់ ខាងជើងជាប់ស្រុកក្រូចឆ្មា ខាងត្បូងជាប់សង្កាត់វិហារលួង ខាងកើតជាប់ស្រុកតំបែរ ខាងលិចជាប់និងឃុំថ្មពេជ្រ និងឃុំពាមជីលាំង។ ឃុំនេះមានផ្ទៃដីរួមសរុប ១៨,២៥៦ហិចតា ចែកចេញជា ផ្ទៃដីលំនៅដ្ឋានរបស់ប្រជាជនមានចំនួន ២,៧៨៥ហិចតា ផ្ទៃដីផលិតកម្មដំណាំស្រូវវស្សាចំនួន ២,២៦១ ហិចតា។ សណ្ឋានដីឃុំចែកជាពីរប្រភេទ គឺតំបន់វាលទំនាបសម្រាប់ផលិតកម្មដំណាំស្រូវ និងតំបន់ខ្ពង់រាបដែលជាផ្ទៃដីសម្រាប់ប្រជាជនធ្វើចំការ និងដាំដំណាំផ្សេងៗ។ ឃុំកាពប្រាំមានហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍សំខាន់ៗរួមមានដូចជា ផ្លូវក្រាលកៅស៊ូមួយខ្សែមានប្រវែង១,៥០០ម ផ្លូវក្រាលគ្រួសក្រហមប្រវែង ២៧,៨១៩ម ផ្លូវដីសប្រវែង ៣៩,២៦៦ម ផ្លូវលំធម្មតាមានប្រវែង ៨២,៧៩០ម។ ដែនទីរដ្ឋបាលឃុំចែកចេញជា ១៨ភូមិ ។ ប្រជាជនសរុបក្នុងឃុំមានចំនួន ៧,៨៥៩ គ្រួសារ ស្មើនឹង ៣០,០២៧ នាក់ ស្រីចំនួន១៥,៦២៥នាក់ ស្ត្រីជាមេគ្រួសារមានចំនួន ៧៩៨នាក់ (តាមទិន្នន័យភូមិឆ្នាំ២០១៦)។ ប្រជាជន ៨៨%នៃគ្រួសារសរុបជាកសិករមានមុខរបរជាកសិកម្មផលិតកម្មដាំដុះស្រូវវស្សា គ្រួសារមានមុខរបរជំនួញ៩% និងគ្រួសារមានមុខរបរកសិកម្មផ្សេងៗមានចំនួន០.៣% ។ ក្រៅពីនេះប្រជាជនជនមានមុខរបរបន្ទាប់បន្សំធ្វើចំការដំឡូងមី ដាំបន្លែបង្ការ និងដំណាំផ្សេងទៀត មុខរបរចិញ្ចឹមសត្វ (គោ ក្របី ជ្រូក មាន់ ទា) និងមានមុខរបរសិប្បកម្មឡើងត្នោតជាដើម។

នៅក្នុងចំណោមប្រជាជនទាំងអស់ក្នុងឃុំប្រជាជនដែលប្រកបរបរកសិកម្មជាចំបងមានចំនួន ១,៩៨២គ្រួសារ ក្នុងនោះ ១,៨៦៧ គ្រួសារធ្វើស្រែចំការជាចំបង ២៣គ្រួសារដាំដំណាំរួមផ្សំជាចំបង ៦១ គ្រួសារប្រកបរបរសិប្បកម្មជាចំបង និងគ្រួសារប្រកបរបរសេវាកម្មជាចំបង ៨៧គ្រួសារ ក្នុងនោះប្រកបរបរជំនួញ ៨៥គ្រួសារ ប្រកបរបរចំរុះ ៦៩គ្រួសារ ។

## ២.២.ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំ

ឃុំសង្កាត់ជានីតិបុគ្គលសាធារណៈដែលមានធនធានសម្រាប់ដំណើរការសកម្មភាពរបស់ខ្លួន។ តាមច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តម្រូវអោយឃុំ សង្កាត់នីមួយៗមានធនធាន ហិរញ្ញវត្ថុ ថវិការ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន[22]។ ឃុំ សង្កាត់មានសិទ្ធិអំណាចគ្រប់គ្រង ហិរញ្ញវត្ថុឃុំ សង្កាត់របស់ខ្លួន និងមានប្រភពចំនូល ចំនាយមួយចំនួនផងដែរ ។

[22] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៧៣។

### ២.២.១.ការរៀបចំ និងការអនុម័តថវិការឃុំ

គម្រោងថវិការត្រូវបានរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំ និងដោយមានជំនួយពីគណៈកម្មាធិការកសាងផែនការ និងថវិការឃុំ សង្កាត់ ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិនិត្យ និងអនុម័ត។ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុម័តគម្រោងថវិការនៃកិច្ចប្រជុំជាសាធារណៈអោយបានមុន ថ្ងៃទី ៣១ ខែតុលា។

ចំពោះឃុំរកាពប្រាំ មុននិងរៀបចំថវិកានេះផងដែរ ឃុំតែងតែធ្វើការប្រឹក្សាយោបល់ពីប្រជាពលរដ្ឋអំពីតម្រូវការរបស់ពួកគាត់ ដើម្បីងាយស្រួលរៀបចំថវិការអោយត្រូវតាមទិសដៅដែលប្រជាពលរដ្ឋនៅក្នុងឃុំចង់បាន និងអោយប្រជាពលរដ្ឋផ្ដិតមេដៃចូលរួមចំណែកក្នុងការដឹងឮផងដែរ។ ជាក់ស្ដែងចំពោះការរៀបចំគម្រោងថវិកាឆ្នាំ ២០១៦ របស់ឃុំរកាពប្រាំ គឺឃុំបានរៀបចំថវិកាចំនួន ១០០,៦០៥,០០០ រៀល សម្រាប់ធ្វើការវិនិយោគនៅក្នុងឃុំ និងសម្រាប់បំពេញនូវតម្រូវការផ្សេងទៀតរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ។

បន្ទាប់ពីការអនុម័តគម្រោងថវិកានៅថ្នាក់ឃុំរួចរាល់ហើយ មេឃុំរកាពប្រាំក៏បញ្ជូនគម្រោងថវិកានោះទៅកាន់អភិបាលខេត្តត្បូងឃ្មុំ។ ក្រោយពេលអភិបាលខេត្តឯកភាពលើគម្រោងថវិកានេះហើយ លោកក៏បញ្ជូនសេចក្ដីជូនដំណឹងជាលាយលក្ខ័អក្សរមកឲ្យលោកមេឃុំវិញ ហើយដើម្បីបញ្ជាក់ពីការទទួលស្គាល់លើគម្រោងថវិកាដែលសេចក្ដីជូនដំណឹងនេះក៏មានចម្លងជូន និងភ្ជាប់ជាមួយគម្រោងថវិកាទៅអោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគាខេត្តផងដែរ ។

### ២.២.២. ចំណូល និងចំណាយថវិការបស់ឃុំ

#### ក. ប្រភពចំណូលរបស់ឃុំ

ឃុំ សង្កាត់មានប្រភពចំណូលចំនួនបីគឺ ចំណូលផ្ទាល់ ចំណូលពីមូលនិធិឃុំ សង្កាត់ និងចំណូលពីការអនុវត្តពីមុខងារ ។

- **ចំណូលផ្ទាល់៖** ឃុំ សង្កាត់ មានសិទ្ធិក្នុងការប្រមូលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធក្នុងមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន ។ ការអនុវត្តកិច្ចនេះរងចាំច្បាប់ដោយឡែកទើបអនុវត្តន៍បាន[23] ។
- **ចំណូលពីមូលនិធិឃុំ សង្កាត់៖** ចំណូលពីមូលនិធិឃុំ សង្កាត់ គឺជាចំណូលដែលបានមកពីការផ្ទេរធនធានពីមូលនិធិឃុំ សង្កាត់ ទៅឲ្យឃុំ សង្កាត់ នីមួយៗដែលក្នុងនោះរួមមាន ចំណូលសម្រាប់ចំណាយរដ្ឋបាល និងចំណាយអភិវឌ្ឍន៍ឃុំ សង្កាត់ [24]។

[23] ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៧៤ ។

- **ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារៈ** ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ គឺជាចំណូល ដែលបានមកពី ការបំពេញការងារដោយឃុំ សង្កាត់ ជំនួសមុខអោយក្រសួង ស្ថាប័ន ឬអង្គភាព នានារបស់រដ្ឋទៅតាមការព្រមព្រៀងគ្នា ។

ក្រៅពីចំណូលទាំងបីខាងលើឃុំ សង្កាត់ មានចំណូលផ្សេងៗទៀតដូចជា ចំណូលពីការរួមចំណែក ពីប្រជាពលរដ្ឋមូលរដ្ឋ ចំណូលពីអង្គការមិនមែនរដ្ឋាភិបាល និងកម្មវិធីនានា។ ចំពោះមុខច្បាប់នៅក្នុង ប្រភពចំណូលថវិការនេះឃុំ សង្កាត់ត្រូវទទួលខុសត្រូវការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ថវិកា និងទ្រព្យ សម្បត្តិ ដើម្បីធានាការប្រើប្រាស់ធនធានអោយបានត្រឹមត្រូវ តម្លាភាពសន្សំសំចៃ និងមានប្រសិទ្ធិភាព ខ្ពស់ ។

**ខ. ចំណាយរបស់ឃុំ**

ឃុំ សង្កាត់មានចំណាយពីរគឺ ចំណាយចរន្ត និងចំណាយមូលធន។

- **ចំណាយចរន្តៈ** ចំណាយចរន្តមានប្រាំពីរប្រភេទគឺ ចំណាយបៀវត្ស និងប្រាក់បំណាច់ ចំណាយ រដ្ឋបាលទូទៅ ចំណាយសេវាសាធារណៈ ចំណាយសម្រាប់មុខងារជាភ្នាក់ងារ ចំណាយ អន្តរាគមន៍ផ្នែកសេដ្ឋកិច្ច និងចំណាយមិនបានគ្រោងទុក ។
- **ចំណាយមូលធនៈ** មានពីរប្រភេទគឺ ចំណាយរដ្ឋបាល និងចំណាយអភិវឌ្ឍន៍។ ចំណាយរដ្ឋបាល គឺជាចំណាយប្រតិបត្តិការ និងវិនិយោគដោយរដ្ឋបាលឃុំ សង្កាត់ ក្នុងការអនុវត្តន៍ភារកិច្ចរួមមាន ប្រាក់បំណាចសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ បៀវត្សមន្ត្រីឃុំ ប្រាក់សម្រាប់ការទិញ ឬជួសជុល និងសម្រាប់ក្រុមប្រឹក្សាឃុំ ការទិញគ្រឿងសង្ហារឹម សម្ភារៈមធ្យោបាយរដ្ឋបាល ការជួសជុល និង ថៃទាំសម្ភារមធ្យោបាយរដ្ឋបាល ថ្លៃប្រើទឹកភ្លើង ទិញ ឬជួសជុលយានជំនិះ និងការចំណាយផ្សេ ងៗ ។ ចំណែកឯចំណាយអភិវឌ្ឍន៍វិញ គឺជាការចំណាយទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធ័ មូលដ្ឋាន និងការផ្តល់សេវាសង្គមកិច្ចដែលក្នុងនោះរួមមាន ការអង្កេតគំនូសប្លង់ ការសាងសង់ ការជួសជុល ការថៃទាំផ្លូវ ផ្សារ មណ្ឌលសុខភាព សាលារៀន មជ្ឈមណ្ឌលសហគមន៍ សំណង់ ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធផ្គត់ផ្គង់ទឹក ថាមពល ហេដ្ឋារចនាសម្ពន្ធ័ សេដ្ឋកិច្ចមន្ត្រីបុគ្គលិកកិច្ចការ ខាងលើ កម្មវិធីអភិវឌ្ឍន៍សហគមន៍ បរិស្ថាន និងធនធានធម្មជាតិ ។

[24] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៧៨ ។

## ២.២.៣.ប្រព័ន្ធទូទាត់ គណនេយ្យ និងកិច្ចលទ្ធកម្មឃុំ សង្កាត់

### ក.គោលការទូទៅ

ឃុំ សង្កាត់ត្រូវបង្កើតគណនីប្រាក់បញ្ញើនៅរតនាគារខេត្តក្រុង[25]។ ហើយមេឃុំ ចៅសង្កាត់ជាអាណាប័ក និង មានសិទ្ធិពេញលេញលើការប្រមូល ឬ សន្យាចំនាយ និង បញ្ជាចំណាយ ដោយផ្អែកលើថវិកាដែលបានអនុម័ត។ មេឃុំ ចៅសង្កាត់ អាចផ្ទេរសិទ្ធិក្នុងការសម្រេចលើថវិកាទៅអោយជំទប់ ឬចៅសង្កាត់រង របស់រដ្ឋបាលឃុំ សង្កាត់។ ការផ្ទេរសិទ្ធិជាអាណាប័កនេះ ត្រូវធ្វើសកម្មភាពដោយស្ថិតក្នុងការទទួលខុសត្រូវ និងត្រួតពិនិត្យរបស់មេឃុំ ចៅសង្កាត់។ មេឃុំ ចៅសង្កាត់ និងអ្នកទទួលសិទ្ធិត្រូវតែតម្កល់គម្រូហត្ថលេខាជាផ្លូវការដល់គណនេយ្យករមុខការ[26]។ ហើយអ្នកទទួលសិទ្ធិ និងបុគ្គលិករដ្ឋបាលឃុំ សង្កាត់ជាទូទៅមិនត្រូវអនុញ្ញាតអោយកាន់កាប់មូលនិធិ ឬ ធ្វើការទូទាត់ចំនាយ លើកលែងតែក្នុងករណីទូទាត់បេឡាបុរេប្រទាន និងចំណូលដែលប្រមូលបាន ដោយភ្នាក់ងារប្រមូលចំណូល។ លើសពីនេះទៅទៀតសិទ្ធិបញ្ជាចំណាយ និងការទូទាត់ មិនត្រូវប្រគល់អោយមនុស្សតែម្នាក់បានឡើយ ហើយរតនាគារខេត្តក្រុងត្រូវបំពេញមុខងារជាគណនេយ្យករឃុំ សង្កាត់។

### ខ. ប្រព័ន្ធទូទាត់

ការទូទាត់ផ្ទាល់ គឺគេទូទាត់តាមរយៈរតនាគារខេត្តក្រុង ហើយការទូទាត់តាមរយៈបេឡាបុរេប្រទានត្រូវប្រើសម្រាប់តែចំនាយចរន្ត (លើកលែងប្រាក់បៀវត្ស ប្រាក់បំណាច់) និងចំនាយវិនិយោគរដ្ឋបាល។ ហើយការចំនាយមួយលើកៗ ចេញពីបេឡាបុរេប្រទានត្រូវមានចំនួនទឹកប្រាក់នៅក្រោមកម្រិតមួយជាកំណាត់ តាមនីតិវិធីបេឡាបុរេប្រទាន [27]។

### គ. ប្រព័ន្ធគណនេយ្យ

**គណនេយ្យហិរញ្ញវត្ថុៈ** គឺជាកិច្ចបញ្ជីការ រាល់ចំណូលចំនាយនៅក្នុងប្រព័ន្ធគណនេយ្យ។ ហើយអ្នកដែលមានភារកិច្ចអនុវត្តន៍គណនេយ្យហិរញ្ញវត្ថុ គឺគណនេយ្យករនៅរតនាគាររាជធានី ខេត្ត ។

**គណនេយ្យថវិការ** គឺជាការតាមដាន និងរាយការណ៍អំពីការអនុវត្តចំណូល ចំណាយ និងថវិកាដែលមានអនុម័ត ។ ហើយអ្នកដែលមានភារកិច្ចទទួលខុសក្នុងការអនុវត្តគណនេយ្យថវិការ គឺមេឃុំ ចៅសង្កាត់[28] ។

---

[25] អនុក្រឹត្យលេខ ២៦ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់,មាត្រា២៩។

[26] អនុក្រឹត្យលេខ ២៦ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់,មាត្រា២៧។

[27] អនុក្រឹត្យលេខ ២៦ អន.ក្របកស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់,មាត្រា៣១។

[28] អនុក្រឹត្យលេខ ២៦ អន.ក្របកស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់,មាត្រា២៤។

**ឃ. កិច្ចលទ្ធកម្មឃុំ សង្កាត់**

កិច្ចលទ្ធកម្ម គឺជាដំណើរការលទ្ធកម្មចាប់ពីពេលរៀបចំឯកសារដេញថ្លៃរហូតដល់ពេញទទួលបានទំនិញ សំណង់ ឬសេវាកម្ម។ ចំណែកឯលទ្ធកម្មវិញ សំដៅទៅដល់ការទិញ ឬការរកបាននូវទំនិញ សំណង់ ឬសេវាកម្មតាមរយៈវិធីសាស្ត្រដែលបានកំណត់ ។

គោលការណ៍សំខាន់ៗនៃកិច្ចលទ្ធកម្មមានដូចជា៖

- លទ្ធកម្មសំណង់ លទ្ធកម្មសេវាកម្ម និងលទ្ធកម្មទំនិញត្រូវអនុវត្តក្នុងលក្ខណៈមួយដែលមានតម្លាភាព ប្រសិទ្ធិភាព និងសន្សំសំចៃបំផុតតាមដែលអាចធ្វើទៅបានដោយធានាគុណភាព
- អ្នកទទួលការ អ្នកផ្តល់សេវា និងអ្នកផ្គត់ផ្គង់ត្រូវបានផ្តល់ឱកាសស្មើៗគ្នា ដើម្បីចូលរួមនៅក្នុងដំណើរការដេញថ្លៃក្រោមលក្ខខណ្ឌយុត្តិធម៌ និងស្មើភាព
- លទ្ធផលនៃការដេញថ្លៃត្រូវផ្សព្វផ្សាយជាសាធារណៈ

ចំពោះសមាសភាពគណៈកម្មការលទ្ធកម្មនេះផងដែររួមមានដូចជា មេឃុំ ចៅសង្កាត់ជាប្រធាន ហើយសមជិកក្រុមប្រឹក្សាឃុំ សង្កាត់ ០២រូប ជាសមាជិក និងស្មៀនឃុំ សង្កាត់ដែលបំពេញតួនាទីជាលេខាធិការ ឱ្យគណៈកម្មការលទ្ធកម្មឃុំ សង្កាត់ ។ ដោយឡែកចំពោះ វិធីសាស្ត្រលទ្ធកម្មវិញ គឺត្រូវអនុវត្តន៍ដូចជា ការដេញថ្លៃដោយប្រកួតប្រជែងជាចំហ (ជាសាធារណៈ) ការស្ទង់តម្លៃក្នុងស្រុក និងការទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់ (ការចរចារតម្លៃផ្ទាល់) ។

## ២.៣.ការអភិវឌ្ឍរបស់ឃុំរភាពច្រាំ

### ២.៣.១.ផែនការអភិវឌ្ឍន៍ឃុំ

ផែនការអភិវឌ្ឍន៍ឃុំ គឺមានអាណិត្តប្រាំឆ្នាំ ដូចអាណិត្តក្រុមប្រឹក្សាដែរ ។ ផែនការអភិវឌ្ឍឃុំ ដែលត្រូវប្រើប្រាស់សម្រាប់កំណត់អំពី បញ្ហា តម្រូវការនិងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយរាល់បញ្ហាទាំងនោះ សំដៅឆ្លើយតបទៅនឹងបញ្ហាជាអាទិភាពរបស់ប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាព ។

**ក. ការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់**

ក្រុមប្រឹក្សាឃុំ សង្កាត់ជារដ្ឋបាលដែលនៅដាច់ឆ្ងាយពីរដ្ឋបាលកណ្តាល ប៉ុន្តែជារដ្ឋបាលដែល

នៅជិតប្រជាពលរដ្ឋជាងរដ្ឋបាលដទៃទៀតហើយក៏ដឹងច្បាស់ពីតម្រូវការរបស់ប្រជាពលរដ្ឋ ក៏ដូចជាស្ថានភាពនៃមូលដ្ឋានរបស់ឃុំ សង្កាត់នីមួយៗផងដែរ។ ដូច្នោះ ការអភិវឌ្ឍន៍ក្នុងមូលដ្ឋានរបស់ឃុំ សង្កាត់នីមួយៗត្រូវពឹងផ្អែកលើវិធានការ និងការរៀបចំគម្រោងនានារបស់ឃុំ សង្កាត់នីមួយៗស្របតាមលទ្ធភាពផ្ទាល់ខ្លួនរបស់ឃុំ សង្កាត់នោះ។

ការរៀបចំ អនុម័ត និងអនុវត្តន៍នូវផែនការអនុវត្តឃុំ សង្កាត់ គឺជាភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយគោលបំណងនៃការបង្កើតផែនការអភិវឌ្ឍនេះ គឺដើម្បីកំណត់នូវទស្សនៈវិស័យ កម្មវិធី និងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន[29]។ ថ្វីបើឃុំ សង្កាត់ត្រូវបានកំណត់ អោយរៀបចំនៅផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដោយខ្លួនឯង និងទៅតាមលទ្ធភាពនៃឃុំ សង្កាត់រៀងៗខ្លួនក៏ដោយ តែផែនការអភិវឌ្ឍន៍នេះ គឺត្រូវតែស្របទៅនិងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់ជាតិ[30]។

ផែនការអភិវឌ្ឍន៍ គឺពិតជាមានសារៈសំខាន់ដែលក្រុមប្រឹក្សាឃុំ សង្កាត់ចាំបាច់ត្រូវតែរៀបចំ និងអនុម័ត ហើយធ្វើការកែសម្រួលនូវទិន្នន័យថ្មីៗដែលប្រែប្រួលជារៀងរាល់ឆ្នាំ នៅពេលសិត្ថិក្នុងអាណិត្ត ឬក្នុងឆ្នាំទីមួយនៃអាណិត្តក្រុមប្រឹក្សាដែលទើបនឹងជាប់ឆ្នោត[31]។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី សិត្ថិ និងសំណុំ ឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក៏ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រ និងមធ្យោបាយនានា ដើម្បីបង្កលទ្ធផលអោយមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល[32] ។

ករណីដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ណាមួយ ធ្វើឡើងមិនស្របតាមច្បាប់ទេនោះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងធ្វើការណែនាំអោយក្រុមប្រឹក្សាឃុំ សង្កាត់ កែតម្រូវអោយបានសមស្របក្នុងអំឡុងពេលយ៉ាងយូរ ៤៥ ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលច្បាប់ចម្លងនៃផែនការនោះ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការកែសម្រួលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនអោយបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ[33] ។

### ខ. វដ្តនៃផែនការអភិវឌ្ឍ [34]

វដ្តនៃផែនការអភិវឌ្ឍន៍ឃុំមានប្រាំជំហាន គឺ ១.សេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍន៍ និងថវិកា, ២.កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍ, ៣.សេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ, ៤.ការអនុម័តផែនការអភិវឌ្ឍន៍ឃុំ, ៥.ការវាយតម្លៃអំពីផែនការអភិវឌ្ឍន៍ឃុំ ។

---

[29] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៦០។

[30] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៦១។

[31] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៦២។

[32] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៦៤។

[33] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៦៥។

[34] គណៈកម្មាធិកាជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ,សៀវភៅមេរៀន«ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ»,ទំព័រ៥១,ខែឧសភា,ឆ្នាំ២០០៧។

**ជំហានទី១៖ សេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍន៍ និងថវិកា**

ជាដំបូងគណៈកម្មាធិការកសាងផែនការ និងថវិការជួបប្រជុំនៅថ្នាក់ឃុំ ដើម្បីធ្វើការវិភាគទិន្នន័យភូមិ ទិន្នន័យឃុំ ឯកសារពត៌មាន ស្ថានភាពឃុំ និងទិន្នន័យ ឬពត៌មាន និងប្រើឧបករណ៍វិភាគផ្សេងៗក្នុងការកំណត់អំពីបញ្ហា មូលហេតុនៃបញ្ហា និងដំណោះស្រាយនានាសម្រាប់ពិភាក្សាជាមួយប្រជាពលរដ្ឋ ។ បន្ទាប់មកគណៈកម្មាធិការ ធ្វើការរៀបចំប្រជុំនៅតាមភូមិ ដើម្បីពិភាក្សា និងធ្វើសុពលភាពលើបញ្ហា មូលហេតុ និងដំណោះស្រាយទាំងឡាយដែលបានកំណត់នៅថ្នាក់ឃុំ និងដើម្បីពិភាក្សាកំណត់បញ្ហា ឬតម្រូវការ និងដំណោះស្រាយនានាបន្ថែម ។ បន្ទាប់ពីនោះគណៈកម្មាធិការ ធ្វើការជួបប្រជុំនៅថ្នាក់ឃុំម្តងទៀត ដើម្បីបូកសរុបបញ្ហា មូលហេតុ និងដំណោះស្រាយដែលបានមកពីបណ្តាលភូមិនានា និងពិភាក្សាកំណត់សេចក្តីត្រូវការអភិវឌ្ឍ គោលដៅយុទ្ធសាស្ត្រអភិវឌ្ឍន៍ សកម្មភាពជាអាទិភាព ទំហំគម្រោង ទីតាំងគម្រោង និងតម្លៃប៉ាន់ស្មានគម្រោង ។

**ជំហានទី២ ៖ កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍ**

កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍឃុំ ត្រូវបានរៀបចំឡើងដើម្បីប្រជុំជាមួយប្រជាពលរដ្ឋនៅក្នុងឃុំនិងអ្នកពាក់ព័ន្ធនានាផ្តល់មតិយោបល់ទៅលើសេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍន៍និងថវិការបស់ឃុំ។

**ជំហានទី៣ ៖ សេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ**

គណៈកម្មាធិការកសាងផែនការ និងថវិការៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ ហើយដាក់ជូនក្រុមប្រឹក្សាឃុំ ដើម្បីពិនិត្យ និងឯកភាព ។ បន្ទាប់ពីទទួលបានឯកភាព មេឃុំផ្ញើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំជូនអភិបាលខេត្តត្បូងឃ្មុំ តាមរយៈអង្គភាពរដ្ឋបាលមូលដ្ឋានខេត្តត្បូងឃ្មុំដើម្បីពិនិត្យ និងផ្តល់យោបល់ ។

**ជំហានទី៤ ៖ ការអនុម័តផែនការអភិវឌ្ឍន៍ឃុំ**

គណៈកម្មាធិការកសាងផែនការ និងថវិកា និងស្មៀនឃុំ ពិនិត្យ ពិចារណា និងកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំទៅតាមមតិយោបលរបស់អភិបាលខេត្តត្បូងឃ្មុំ។ ក្រោយមកទៀតក្រុមប្រឹក្សាឃុំធ្វើការពិនិត្យ និងអនុម័តសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ។ ឯកសារផែនការអភិវឌ្ឍឃុំដែលបានអនុម័ត ត្រូវផ្សព្វផ្សាយជាសាធារណៈ និងប្រើប្រាស់ជាមូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគប្រចាំឆ្នាំ ។

**ជំហានទី៥ ៖ ការវាយតម្លៃអំពីផែនការអភិវឌ្ឍន៍ឃុំ**

គណៈកម្មាធិការកសាងផែនការ និងថវិកា ពិនិត្យ និងវាយតម្លៃទៅលើប្រសិទ្ធិភាពនៃការអនុវត្តផែនការអភិវឌ្ឍឃុំ និងដកស្រង់បទពិសោធន៍នានា សម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រងការអនុវត្ត និងការរៀបចំផែនការពេលក្រោយ ។

### គ.ការអនុវត្តផែនការអភិវឌ្ឍន៍

នៅពេលអនុវត្តន៍គម្រោង ក្រុមប្រឹក្សាឃុំ ត្រូវធានាថាគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ពិសេសអ្នកទទួលផលពីគម្រោងបានចូលរួមយ៉ាងពេញលេញ នៅក្នុងការរៀបចំគម្រោង និងការត្រួតពិនិត្យការអនុវត្តគម្រោងដែលមានក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ។ មេឃុំត្រូវធ្វើលទ្ធកម្មការងារ សាងសង់សម្ភារៈ ឬទំនិញ និងសេវាកម្មដើម្បីអនុវឌ្ឍន៍គម្រោងទាំងអស់ និងសកម្មភាពនានាអោយស្របទៅតាមនីតិវិធីដែលបានកំណត់។ មុនធ្វើលទ្ធកម្មការងារសាងសង់ សម្ភារៈ ឬទំនិញ និងសេវាកម្មសម្រាប់អនុវត្តន៍គម្រោងណាមួយ មេឃុំត្រូវស្វែងរកការបញ្ជាក់ផ្នែកបច្ចេកទេសពីមន្ទីរជំនាញ ឬអង្គភាពពាក់ព័ន្ធជុំវិញខេត្ត តាមរយៈអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត។ ការវាយតម្លៃគ្រប់ជ្រុងជ្រាយទៅលើលទ្ធផល និងផលប៉ះពាល់ពីការអនុវត្តផែនការអភិវឌ្ឍឃុំ ត្រូវធ្វើឡើងក្នុងរយៈពេល ០៦ ខែចុងក្រោយនៃអណិត្តរបស់ក្រុមប្រឹក្សា ។

### ឃ. ការត្រួតពិនិត្យ និងវាយតម្លៃ

បន្ទាប់ពីការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ រួចក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើសកម្មភាពនៃការអនុវត្តផែនការអភិវឌ្ឍ កម្មវិធីគម្រោង និងការផ្តល់សេវាសាធារណៈនានារបស់ឃុំ សង្កាត់ ប្រកបដោយតម្លាភាព ជាមួយនឹងការទទួលខុសត្រូវខ្ពស់របស់អ្នកផ្តល់សេវា [35]។ ដោយស្របទៅតាមស្ថានភាពជាក់ស្តែង ក្រុមប្រឹក្សាឃុំ សង្កាត់អាចនឹងជ្រើសរើសយកសមាសភាពផ្សេងទៀតមកអនុវត្តន៍ផែនការ កម្មវិធី និងគម្រោងនានារបស់ឃុំ សង្កាត់ ប៉ុន្តែក្រុមប្រឹក្សាឃុំ សង្កាត់ នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃចំពោះការអនុវត្តរបស់សមាសភាពនោះ[36]។

ម្យ៉ាងទៀត ដើម្បីបង្កើនប្រសិទ្ធិភាពនៃការអនុវត្តផែនការរបស់ឃុំ សង្កាត់ « រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីវិធីសាស្ត្រផ្សេងៗក្នុងការអនុវត្តផែនការ និងក្នុងការត្រួតពិនិត្យវាយតម្លៃរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះការប្រើប្រាស់មូលនិធិសម្រាប់ផែនការអភិវឌ្ឍឃុំសង្កាត់ » [37]

[35] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៦៦។

[36] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៦៧។

[37] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៦៨។

## ២.៣.២.កម្មវិធីវិនិយោគរបស់ឃុំ

### ក. ក្របខណ្ឌវិនិយោគ [38]

ដើម្បីចូលរួមចំណែកអោយបានជោគជ័យ តាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ការចូលរួមចំណែកក្នុងបរិបទនេះ គឺជាភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការកសាងផែនការនិងថវិការឃុំធ្វើយ៉ាងណាកំណត់អោយបានច្បាស់លាស់អំពីក្របខណ្ឌនៃការវិនិយោគ។

ដោយតួនាទីឬភារកិច្ចជាអ្នកទទួលខុសត្រូវលើកិច្ចការអភិវឌ្ឍន៍ឃុំ គណៈកម្មាធិការកសាងផែនការ និងថវិការបានរៀបចំប្រជុំផ្សព្វផ្សាយពីដំណើរការកសាងកម្មវិធីវិនិយោគឃុំឆ្នាំ២០១៦ ព្រមទាំងមានការចូលរួមពីប្រជាពលរដ្ឋ ក្នុងការធ្វើសេចក្ដីសម្រេចចិត្តជាសាធារណៈ ជាពិសេសគឺការអនុវត្តគោលនយោបាយជាតិធ្វើអោយមានកំណើនសេដ្ឋកិច្ច ដោយចីរភាពក្នុងការកាត់បន្ថយភាពក្រីក្រ។ ដើម្បីអោយមានភាពជាក់ស្ដែងពិតប្រាកដ ក្នុងការឈានទៅសម្រេចបានខ្លឹមសារដូចខាងក្រោម៖

- កែលម្អផ្លូវជនបទចំនួនមួយខ្សែ និងសាងសង់លូកាត់ផ្លូវបើកន្លែង
- បង្កើតវគ្គបណ្ដុះបណ្ដាល និងបច្ចេកទេសចិញ្ចឹមសត្វ
- ស្ដារឡើងវិញ និងកែលម្អប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ដើម្បីធានាការផ្គត់ផ្គង់ទឹកបញ្ចូលក្នុងស្រែរបស់កសិករដែលជួបប្រទះបញ្ហាកង្វះទឹកស្រោចស្រប
- បង្កើន និងធានាអោយបានសុវត្ថិភាពផលិតកម្មសត្វ
- បង្កើន និងធានាអោយបានសុវត្ថិភាពផលិតកម្មដំណាំកសិកម្មគ្រប់ប្រភេទ
- បង្កើនការផ្គត់ផ្គង់អគ្គិសនីអោយបានគ្រប់គ្រាន់ដោយកំណត់ថ្លៃសមរម្យ
- ធានាផ្ដល់សេវាថែទាំសុខភាពដល់ប្រពលរដ្ឋប្រកបដោយគុណភាព និងសមធម៌ឆ្ពោះទៅកាត់បន្ថយនូវអត្រាឆ្លងមេរោគគ្រប់ប្រភេទ និងអត្រាមរណៈមាតា និងទារក
- អភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការគាំទ្រ និងបណ្ដុះបណ្ដាលក្នុងមូលដ្ឋាន
- គ្រប់គ្រងការបញ្ចេញសំណល់ រឹង រាវ សំរាម និងកាត់បន្ថយជាតិពុលគ្រប់ប្រភេទ
- ធានាការបញ្ជ្រាប និងការយល់ដឹងអំពីយេនឌ័រឆ្ពោះទៅរកការលើកកម្ពស់សមធម៌គ្រប់បញ្ហារវាងស្ត្រីនិងបុរស ។

### ខ. វដ្ដនៃកម្មវិធីវិនិយោគ [39]

វដ្ដនៃកម្មវិធីវិនិយោគឃុំរកាពប្រាំមានប្រាំជំហានគឺ

[38] សៀវភៅ,ក្របខណ្ឌវិនិយោគឃុំរកាពប្រាំ,ប្រចាំឆ្នាំ២០១៦។

[39] គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ,សៀវភៅមេរៀន«ការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់តាមបែបវិមជ្ឈការ»,ទំព័រ៥៩,ខែឧសភា,ឆ្នាំ២០០៧។

**ជំហានទី១ ៖ ការពិនិត្យបញ្ហា ឬតម្រូវការរបស់ប្រជាពលរដ្ឋឡើងវិញ**

គណៈកម្មាធិការកសាងផែនការ និងថវិការជួបប្រជុំនៅថ្នាក់ឃុំ ដើម្បីពិភាក្សាពិនិត្យ បញ្ហា ឬតម្រូវការ មូលហេតុនៃបញ្ហា និងដំណោះស្រាយឡើងវិញ ដោយធ្វើការឆ្លុះបញ្ចាំងជាមួយទិន្នន័យភូមិ ទិន្នន័យឃុំ ឯកសារពត៌មានស្ថានភាពឃុំ និងទិន្នន័យ ឬពត៌មានផ្សេងៗ ហើយកំណត់អំពីរមូលហេតុនៃបញ្ហា និងដំណោះស្រាយនានាសម្រាប់ពិភាក្សាជាមួយប្រជាពលរដ្ឋ ។ បន្ទាប់មកគណៈកម្មាធិការធ្វើការរៀបចំប្រជុំនៅតាមភូមិ ដើម្បីពិភាក្សា និងធ្វើសុពលភាពទៅលើបញ្ហា មូលហេតុ និងដំណោះស្រាយទាំងឡាយដែលបានកំណត់នៅថ្នាក់ឃុំ និងដើម្បីពិភាក្សាកំណត់បញ្ហា ឬតម្រូវការ និងដំណោះស្រាយនានាបន្ថែម ។ ក្រោយមកគណៈកម្មាធិការធ្វើការជួបប្រជុំម្តងទៀតនៅថ្នាក់ឃុំ ដើម្បីបូកសរុបបញ្ហាមូលហេតុ និងដំណោះស្រាយដែលបានមកពីបណ្តាភូមិនានា ។

**ជំហានទី២ ៖ ការរៀបចំគម្រោងវិនិយោគឃុំ សង្កាត់**

គណៈកម្មាធិការកសាងផែនការ និងថវិការ ធ្វើការឆ្លុះបញ្ចាំងលទ្ធផលនៃជំហានទីមួយ ជាមួយនិងគម្រោងតាមបណ្តាលឆ្នាំនីមួយៗនៃផែនការអភិវឌ្ឍន៍ឃុំ ដើម្បីកំណត់គម្រោងវិនិយោគប្រចាំឆ្នាំដែលត្រូវយកទៅបង្ហាញ និងកៀរគរធនធាននៅសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ។

**ជំហានទី៣ ៖ សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ**

សិក្ខាសាលាសមាហរណកម្មផែនការនេះត្រូវបានរៀបចំឡើងដើម្បីៈ

- ផ្តល់ឪកាសអោយមានការផ្សារភ្ជាប់កម្មវិធីវិនិយោគឃុំ ជាមួយនិងផែនការរបស់មន្ទីរជំនាញអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូរអភិវឌ្ឍន៍នានា
- កៀរគរ និងសម្របសម្រួលធនធានពីប្រភពផ្សេងៗសម្រាប់គាំទ្រដល់គម្រោងវិនិយោគ
- ជួយតម្រង់ទិសសកម្មភាពរបស់មូលដ្ឋានឃុំ អោយស្របតាមគោលនយោបាយអភិវឌ្ឍន៍ជាតិ និងខេត្ត

**ជំហានទី៤ ៖ ការអនុម័តកម្មវិធីវិនិយោគឃុំ សង្កាត់**

គណៈកម្មាធិការកសាងផែនការ និងថវិកា រៀបចំតារាងថវិកាវិនិយោគតាមប្រភព តារាងគម្រោងវិនិយោគដែលមានការសន្យាគាំទ្រ ព្រមទាំងជ្រើសរើសគម្រោងដែលមិនទាន់មានការសន្យាគាំទ្រ សម្រាប់ប្រើប្រាស់មូលនិធិឃុំ។ បន្ទាប់មកគណៈកម្មាធិការ ត្រូវរៀបចំប្រជុំផ្សព្វផ្សាយនៅតាមភូមិ ដើម្បីអោយប្រជាពលរដ្ឋផ្តល់យោបល់លើគម្រោងប្រចាំឆ្នាំ ជាពិសេសគម្រោងប្រើប្រាស់មូលនិធិឃុំ។ ក្រោយពីមូលមតិយោបល់រួច គណៈកម្មាធិការត្រូវរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគឃុំ ហើយដាក់ជូនក្រុមប្រឹក្សាឃុំ ដើម្បីពិនិត្យ និងអនុម័ត ។

ឯកសារកម្មវិធីវិនិយោគដែលអនុម័តរួច ត្រូវប្រកាសផ្សព្វផ្សាយដាក់អោយប្រើប្រាស់ជាផ្លូវការ និងបង្កភាពងាយស្រួលដល់អ្នកពាក់ព័ន្ធធ្វើការសិក្សាស្វែងយល់ ។

**ជំហានទី៥ ៖ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ ឃុំ សង្កាត់**

ជំហានចុងក្រោយគណៈកម្មាធិការត្រូវតាមដានត្រួតពិនិត្យការរីកចម្រើន និងប្រសិទ្ធិភាពនៃការអនុវត្តគម្រោង ឬសកម្មភាពនានាដែលមាននៅក្នុងកម្មវិធីវិនិយោគឃុំ ដើម្បីធានាការអនុវត្តគម្រោង ឬសកម្មភាពទាំងនោះ អោយបានត្រឹមត្រូវ និងទាន់ពេលវេលា ។ មិនត្រឹមតែប៉ុណ្ណោះ គណៈកម្មាធិការក៏ត្រូវពិនិត្យ និងវាយតម្លៃលើប្រសិទ្ធិភាពនៃការអនុវត្តកម្មវិធីវិនិយោគឃុំ និងដកស្រង់បទពិសោធន៍នានាសម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រងការអនុវត្ត និងការរៀបចំកម្មវិធីវិនិយោគឆ្នាំក្រោយ ។

**គ. គម្រោងវិនិយោគ**

ដោយការប្រើប្រាស់ថវិកាវិនិយោគដែលបានមកពី ទុនចូលរួមរបស់ប្រជាពលរដ្ឋចំនួន ១,០០០,០០០៛ និងទុនដែលបានមកពីមូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ចំនួន ១០០,៦០៥,០០០៛ ទើបគម្រោងវិនិយោគជាច្រើនត្រូវបានដំណើរការ ដោយបែងចែកជាគម្រោងវិនិយោគដែលមានការសន្យាគាំទ្រ និងគម្រោងវិនិយោគដែលពុំទានមានការសន្យាគាំទ្រ ។ គម្រោងវិនិយោគដែលមានការសន្យាគាំទ្រភាគច្រើនអនុវត្តន៍ទៅលើ ផ្នែកសង្គមកិច្ច ផ្នែកសេវារដ្ឋបាល និងសន្តិសុខ និងផ្នែកយ៉េនឌ័រប៉ុណ្ណោះ។ ដោយឡែកផ្នែកធនធានមនុស្ស និងបរិស្ថាន ផ្នែកសេដ្ឋកិច្ចពុំទាន់មានគម្រោងគាំទ្រនៅឡើយទេ។ ចំពោះគម្រោងដែលមានការសន្យាគាំទ្រមានដូចជា គម្រោងសាងសង់អណ្តូង ជួសជុលអណ្តូងស្នប់ បញ្ជូនអ្នកជំងឺភ្នែកទៅវះកាត់ភ្នែកនៅមន្ទីរពេទ្យបង្អែកស្រុកត្បូងឃ្មុំ ដោយមិនចាំបាច់យកប្រាក់ ស្វែងរកកុមារពិការភ្នែកទៅរៀនអក្សរស្ទាបនៅគ្រួសារថ្មីខេត្តកំពង់ចាមចាប់ពីអាយុ ០៦ ដល់ ១៤ឆ្នាំ និងបណ្តុះបណ្តាលកិច្ចការនារីឃុំ។ ហើយគម្រោងដែលមានការសន្យាគាំទ្រនេះប្រើប្រាស់ថវិកាដែលបានមកពីមន្ទីរអភិវឌ្ឍន៍។ ចំពោះគម្រោងដែលមិនទាន់មានការគាំទ្រវិញមានដូចជា ការសង់លូកាត់ផ្លូវ ជួសជុលទំនប់ បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក មាន់ ទា គម្រោងសាងសង់ផ្លូវដី បង្កើតទីតាំងចាក់សំរាម គម្រោងទាំងអស់នេះគឺបានប្រើប្រាស់ថវិកាដែលបានមកពីការចូលរួមរបស់ប្រជាពលរដ្ឋ និងមូលនិធិអភិវឌ្ឍន៍ឃុំ ។

# ជំពូកទី ៣

# បញ្ហាប្រឈម និងដំណោះស្រាយ

## ៣.១.បញ្ហាប្រឈម

### ៣.១.១.ផ្នែកកសិកម្ម និងដីធ្លី

ឃុំរកាពប្រាំជាឃុំមួយដែលប្រជាជនរស់នៅពឹងផ្អែកលើវិស័យកសិកម្មជាចម្បង ប៉ុន្តែទោះជាយ៉ាងនេះក្តីប្រជាពលរដ្ឋមួយចំនួនធំធ្វើស្រែចំការតាមប្រពៃណីរបស់ខ្លួន ដោយពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង។ នៅក្នុងឃុំរកាពប្រាំនេះផងដែរផ្ទៃដីដែលធ្វើស្រែវស្សាមានចំនួន ២,២៦១ហិចតាប៉ុន្តែក្នុងនោះមានផ្ទៃដីត្រឹមតែ ៥០ហិចតាប៉ុណ្ណោះដែលមានប្រព័ន្ធធារាសាស្ត្រជាជំនួយក្នុងការធ្វើស្រែចំការ។ ចំណែកឯទិន្នផលស្រូវរដូវវស្សានៅមានកំរិតទាប ប្រជាកសិករមួយចំនួនក៏គ្មានដីធ្វើស្រែហើយក៏គ្មានលទ្ធភាពក្នុងការជួលដីស្រែគេសម្រាប់បង្កបង្កើនផលឡើយ ឯប្រជាកសិករដែលមានដីធ្វើស្រែវិញ ឆ្នាំខ្លះក៏ត្រូវរងការខាតបង់ដោយសារតែភ្លៀងធ្លាក់មិនគ្រប់គ្រាន់ក្នុងការធ្វើស្រែចំការ បញ្ហាទាំងនេះពិតជះឥទ្ធិពលយ៉ាងខ្លាំងដល់ជីវភាពរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ។ មួយវិញទៀតប្រជាពលរដ្ឋនៅក្នុងឃុំពុំសូវមានចំណេះដឹងក្នុងការដាំដុះ និងចិញ្ចឹមសត្វ(ដូចជា ការជ្រើសរើសសត្វ និងរបៀបក្នុងការចិញ្ចឹម) ទើបធ្វើអោយពួកគេជួបប្រទះនូវបញ្ហាជាច្រើនក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

### ៣.១.២.ផ្នែកគមនាគមន៍

ចំពោះផ្នែកគមនាគមន៍វិញនៅតែជាបញ្ហាចម្បងរបស់ប្រជាពលរដ្ឋនៅក្នុងឃុំរកាពប្រាំ ព្រោះតែផ្លូវមួយចំនួនត្រូវបានខូចខាតដោយសារភ្លៀងធ្លាក់ ហើយមួយចំនួនទៀតត្រូវបានខូចខាតដោយសារការដឹកទំនិញធ្ងន់លើសកំណត់ និងរថយន្តធំៗ ហេតុដូចនេះហើយទើបការធ្វើដំណើររបស់ប្រជាពលរដ្ឋត្រូវជួបប្រទះនូវការលំបាកផងដែរ។ លើសពីនេះទៅទៀត បញ្ហាផ្លូវគមនាគមន៍ក៏ធ្វើអោយកើតមាននូវគ្រោះថ្នាក់ចរាចរណ៍ជាបន្តបន្ទាប់នៅក្នុងឃុំ។ ចំណែកឯសេវាដឹកជញ្ជូននៅមានលក្ខណៈមិនទាន់រីកចម្រើននៅឡើយ គឺបណ្តាមកពីកត្តាហេដ្ឋារចនាសម្ពន្ធ័ផ្លូវថ្នល់នៅក្នុងឃុំពុំអំណោយផល ។

### ៣.១.៣.ផ្នែកសុខាភិបាល និងបរិស្ថាន

ស្ថានភាពសុខភាពរបស់ប្រជាជនក្នុងឃុំរការពប្រាំ មិនទាន់ចាត់ទុកថាល្អប្រសើរតាមបំណងប្រថ្នាដែលបានកំណត់ទុកនៅក្នុងគោលដៅដែលឃុំចង់បាននៅឡើយទេ ។ មេរោគ និងជំងឺដែលបណ្តាលមកពីកត្តាផ្សេងៗដែលកើតមានដល់ប្រជាពលរដ្ឋ ដែលនាំអោយគ្រួសារមួយចំនួនធ្លាក់ក្នុងភាពក្រីក្រដោយសារតែចំនាយថវិកាក្នុងការមើលជំងឺ។ លើសពីនេះទៅទៀតនៅក្នុងឃុំ មានមណ្ឌលសុខភាពតែពីរកន្លែងប៉ុណ្ណោះ គឺភូមិវាល់វង់ និងភូមិត្រពាំងឫស្សី ពិសេសនោះគឺមានឧបករណ៍ក្នុងការព្យាបាលពុំ

គ្រប់គ្រាន់ឡើយ ដែលជាហេតុនាំអោយប្រជាពលរដ្ឋត្រូវចំនាយថវិកាច្រើនដើម្បីទៅព្យាបាលនៅទីរួមខេត្ត។ ដោយសារតែមណ្ឌលសុខភាពនៅក្នុងឃុំមានតែពីរ ដូច្នេះហើយទើបធ្វើអោយស្រ្តីមួយចំនួនដែលរស់នៅក្នុងភូមិឆ្ងាយពីមណ្ឌលសុខភាពត្រូវសំរាលកូនដោយឆ្មបបុរាណដែលអាចនាំអោយមានផលប៉ះពាល់ដល់អាយុជីវិតម្តាយ និងទារក ធ្វើអោយជួបប្រទះបញ្ហាសុខភាពទ្រុឌទ្រោមចំនាយថវិកាច្រើនក្នុងការព្យាបាលជំងឺ ឬអាចឈានទៅដល់ការបាត់បង់នូវធនធានមនុស្សទៀតផង។ បញ្ហាមួយទៀតនោះក៏ជាបញ្ហាចំបងផងដែល គឺនៅក្នុងភូមិប្រជាពលមានផ្ទុកជំងឺអេដស៍ កុមារកំព្រាក្រោមអាយុដប់ប្រាំបីឆ្នាំ ចាស់ជរាគ្មានទីពឹង ជនពិការមិនអាចរកប្រាក់ចំណូលបាន ដែលជាបន្ទុកយ៉ាងធ្ងន់ធ្ងររបស់ឃុំក្នុងការដោះស្រាយ ដើម្បីសម្រាលបន្ទុកដល់ក្រុមគ្រួសាជនរងគ្រោះ។

លើសពីនេះទៅទៀតបញ្ហាមួយទៀតដែលយើងគួរយកចិត្តទុកដាក់នោះ គឺបញ្ហាបរិស្ថានដោយសារឃុំពុំមានទីតាំងចាក់សម្រាម ធ្វើអោយប្រជាពលរដ្ឋយកសំរាមចាក់ចោលតាមចញ្ចើមថ្នល់ពាសវាលពាសកាលជាហេតុធ្វើអោយប៉ះពាលដល់បរិស្ថាន និងជាកត្តាចម្លងរោគដល់ប្រជាពលរដ្ឋផងដែរ ។ ដោយសារតែនៅក្នុងឃុំមានអណ្តូងដែលត្រូវជួសជុល និងអណ្តូងដែលត្រូវស្តាដល់ទៅប្រាំបួន ហើយនឹងអណ្តូងលូចំនួនពីរ។ ហេតុដូចនេះហើយបានជាប្រជាជនត្រូវទទួលទានទឹកពីប្រភពមិនស្អាតមានដល់ទៅ ៥,៧៣២គ្រួសារ ដែលបញ្ហានេះធ្វើអោយប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋនៅក្នុងឃុំជាខ្លាំង ធ្វើអោយប្រជាពលរដ្ឋកាន់តែជួបប្រទះការលំបាកដោយសារបញ្ហាសុខភាពមិនអំណោយផល។ មួយវិញទៀតប្រជាពលរដ្ឋនៅក្នុងឃុំពុំសូវយល់ដឹងអំពីអនាម័យក្នុងការរស់នៅប្រចាំថ្ងៃដែលជាហេតុបង្កឱ្យពួកគាត់ជួបប្រទះនូវបញ្ហាសុខភាពជាបន្តបន្ទាប់។

### ៣.១.៤.ផ្នែកអប់រំ

ការអប់រំជាតម្រូវការបន្ទាន់ និងចាំបាច់សម្រាប់ការអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងឃុំ សង្កាត់អោយកាន់តែមានការរីកចម្រើន។ ប៉ុន្តែស្ថានភាពអប់រំនៅក្នុងឃុំរកាពប្រាំមិនទាន់ល្អប្រសើរឡើយ ដោយសារនៅក្នុងឃុំ មានសាលាមតេយ្យសិក្សាចំនួន ០៤ សាលាតែប៉ុណ្ណោះ។ ចំណែកកុមារដែលមានអាយុពី ០៦ ដល់ ១១ឆ្នាំ មិនបានទៅរៀនសរុប ២៨៧នាក់ស្មើ ១៨% (ប្រុស១៤២នាក់ ស្រី១៤៥នាក់) ។ មិនតែប៉ុណ្ណោះនៅក្នុងឃុំមានអ្នកមិនចេះអក្សរក្នុងកម្រិតអាយុ ១៥ ដល់ ៦០ឆ្នាំសរុប ៣,១៤៥នាក់ ក្នុងនោះស្រីមានចំនួន ១,៥៤៣នាក់ ។ កត្តាទាំងអស់នេះកើតឡើងដោយសារតែនៅក្នុងឃុំពុំសូវមានសាលាច្រើន ហើយប្រជាជនមួយចំនួនមានជីវភាពពុំសូវធូរធារទើបធ្វើអោយប្រជាជនក្នុងឃុំពុំសូវមានអ្នកចេះដឹង ហើយនេះក៏ជាបញ្ហាដែលឃុំត្រូវទទួលរ៉ាប់រងផងដែរ ។

### ៣.១.៥.ផ្នែកសន្តិសុខ និងសណ្តាប់ធ្នាប់

នៅក្នុងឃុំរកាពប្រាំពេលខ្លះតែងជួបប្រទះនិងបញ្ហាអសន្តិសុខនៅតាមបណ្តាលភូមិ ដោយសារក្មេងទំនើងដើរលេងយប់ ការសេពគ្រឿងស្រវឹង និងបញ្ហាគ្រោះថ្នាក់ចរាចរណ៍ជាដើម។ ទោះបីជាយុវជនជាច្រើនបានទទួលការអប់រំពីសាលា ប៉ុន្តែយុវជនមួយចំនួនតូចបានបង្កើតបក្សពួកដើរលេងពេលយប់ ហើយតែងបង្កនូវជម្លោះដល់កម្មវិធីបុណ្យទាន កម្មវិធីរៀបអាពាហ៍ពិពាហ៍ និងកម្មវិធីផ្សេងទៀតដែលមានចាក់ធុងបាសលេងពេលយប់ បណ្តាលអោយមានការវាយតប់បង្ករបួសស្នាម ឬការកាប់ចាក់សម្លាប់ក៏មាន។ មួយវិញទៀតប្រជាពលរដ្ឋមួយចំនួនបានប្រើអំពើហឹង្សាក្នុងគ្រួសាររហូតដល់ការលែងលះក៏មាន។ មិនតែប៉ុណ្ណោះ ឃុំរកាពប្រាំមានការប្រឈមខ្ពស់ចំពោះបញ្ហាគ្រោះថ្នាក់ចរាចរណ៍ដោយសារការបើកបរពេលស្រវឹង ការបើកបរលឿនហួសល្បឿនកំណត់ និងការបើកបរមិនគោរពវិធានផ្សេងៗទៀតនៃច្បាប់ចរាចរណ៍ផ្លូវគោក។ ទទ្ទឹមនិងបញ្ហាខាងលើ ការរក្សាសន្តិសុខសណ្តាប់ធ្នាប់ក្នុងឃុំរកាពប្រាំនៅជួបប្រទះនូវបញ្ហាមួយចំនួនទៀតដូចជា ល្បែងស៊ីសង បញ្ហាគ្រឿងញៀន និងការលួចឆក់ប្លន់ជាដើម ។

### ៣.១.៦.ផ្នែកការងាររដ្ឋបាល និងការចូលរួមរបស់ប្រជាពលរដ្ឋ

នៅក្នុងឃុំរកាពប្រាំ រាល់ការបំពេញការងារបានជួបប្រទះនូវបញ្ហាជាច្រើនដូចជា ប្រជាជនមួយចំនួនមិនទាន់មានសំបុត្របញ្ជាក់កំណើត បច្ចេកទេសក្នុងការរៀបចំកសាងឯកសារនៅមានកម្រិត និងការងារមួយចំនួនមិនបានអនុវត្តន៍តាមច្បាប់ជាធរមានជាដើម។ មួយវិញទៀតប្រជាពលរដ្ឋពុំសូវមានសកម្មភាពក្នុងការចូលរួមកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សាឃុំនោះទេ។ ការមិនបានតាមដានសកម្មភាពរបស់អាជ្ញាធរឃុំដូច្នោះ គឺជាកង្វះការទទួលខុសត្រូវមួយរបស់ប្រជាពលរដ្ឋខ្លួនឯងដែលជាម្ចាស់ឆ្នោតក្នុងការចូលរួមសម្រេចចិត្តដើម្បីអភិវឌ្ឍន៍ក្នុងមូលដ្ឋានឃុំដែលខ្លួនរស់នៅ។ មួយវិញទៀតចំពោះការរៀបចំកសាងឯកសាររបស់ឃុំក៏នៅមានកម្រិតដែលជាហេតុនាំអោយការរៀបចំឯកសារនៅមានលក្ខណៈពុំទាន់ត្រឹមត្រូវគ្រប់ជ្រុងជ្រោយនៅឡើយ ។ លើសពីនេះទៅទៀតនោះ គឺមន្ត្រីមួយចំនួនមានចំណេះដឹងផ្នែកបច្ចេកទេសតិចដោយសារតែពុំសូវទទួលបានការបណ្តុះបណ្តាលបន្ថែម។

## ៣.២.ដំណោះស្រាយ

### ៣.២.១.ការពង្រឹងវិស័យកសិកម្ម និងដីធ្លី

ដោយឃុំរកាពប្រាំជាឃុំដែលពឹងផ្អែកលើវិស័យកសិកម្ម ដូច្នេះបញ្ហាដីធ្លីគឺជាបញ្ហាមួយដែលសំខាន់ដែលឃុំ គួរយកចិត្តទុកដាក់ក្នុងការដោះស្រាយ ហើយដើម្បីដោះស្រាយនៅរាល់បញ្ហាដែលកើតមាន ឃុំក៏ មានគម្រោងផ្តល់ជូនប្រជាពលរដ្ឋនូវៈ

- ឥណទានសាច់ប្រាក់ដែលមានការទាប
- ឥណទានសត្វផ្ដល់ពូជសត្វល្អៗ
- បណ្ដុះបណ្ដាលបច្ចេកទេសដាំដុះ និងចិញ្ចឹមសត្វ
- បង្កើតអោយមានពេទ្យសត្វប្រចាំភូមិ

ចំពោះដំណាំរួមផ្សំឃុំមានផ្ទៃដីចំនួន៥២៨ហិចតា និងមានដំណាំចំការផ្សេងៗទៀតដែលអាចបំផុសអោយប្រជាជនប្រើប្រាស់ក្នុងការដាំដំណាំបន្ថែមទៀតក្រៅពីធ្វើស្រែចំការដើម្បីជួយដោះស្រាយជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ អោយកាន់តែមានភាពល្អប្រសើរជាងមុន។

### ៣.២.២.ការកែលម្អប្រព័ន្ធគមនាគមន៍

ដូចយើងដឹងស្រាប់ហើយប្រព័ន្ធគមនាគមន៍ជាចំណែកមួយដ៏សំខាន់ដល់ការរស់នៅ ដូច្នេះ ការលំបាកដែលមានចំពោះមុខ ឃុំក៏សម្រេចចិត្តជួសជុលផ្លូវដែលក្រាលគ្រួសក្រហមប្រវែង ៧,៨០០ម ផ្លូវលំប្រវែង ៩,៨៨០ម និងត្រូវលើកផ្លូវថ្មីដូចជា ផ្លូវក្រាលគ្រោះក្រហមប្រវែង ២២,៦៦៣ម ផ្លូវដីស ១៨,១០០ម ចូលទៅក្នុងកម្មវិធីវិនិយោគរបស់ឃុំ ព្រមទាំងទំនាក់ទំនងជាមួយ សប្បុរសជននានា និងអង្គការក្រៅរដ្ឋាភិបាលដើម្បីជួយគ្រាំទ្រដល់ឃុំ និងជួយសម្រួលដល់ការដឹកទំនិញ និងសកម្មភាពសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋនៅក្នុងឃុំរកាពប្រាំ ។ ទាំងអស់នេះ គឺក្នុងគោលបំណងដើម្បីជួយដោះស្រាយនូវបញ្ហាដែលប្រជាពលរដ្ឋនៅក្នុងឃុំជួបប្រទះ។

### ៣.២.៣.ការថែទាំសេវាសុខាភិបាល និងបរិស្ថាន

ឃុំរកាពប្រាំ និងធ្វើការកែលម្អសេវាសុខភាពដែលផ្ដល់តាមរយៈ មណ្ឌលសុខភាព ការអប់រំប្រជាជននៅក្នុងឃុំអោយយល់ដឹងពីសារសំខាន់នៃការនាំកូនមកចាក់ថ្នាំបង្ការ កែប្រែទំលាប់ពីសម្រាលកូនដោយឆ្មបបុរាណ អោយមកប្រើប្រាស់សេវាពេទ្យឆ្មបដែលធានាសុវត្ថិភាពជាមួយបុគ្គលិកសុខាភិបាលដែលមានជំនាញច្បាស់លាស់ ។ លើសពីនេះទៅទៀតដើម្បីដោះស្រាយបញ្ហាដែលទាក់ទង និងសុខភាពរបស់ប្រជាពលរដ្ឋនោះគឺត្រូវបណ្ដុះបណ្ដាដល់ពេទ្យឆ្មប់ដែលមានស្រាប់ជាប្រចាំអោយមានចំនេះដឹងបន្ថែមទៅលើជំនាញរបស់ខ្លួន និងផ្ដល់សម្ភារៈ ឧបករណ៍ សម្រាប់ជំនួយលើការបម្រើសេវាសុខភាពជូនប្រជាពលរដ្ឋ ។ ធ្វើការផ្សព្វផ្សាយដល់ស្ដ្រីទាំងអស់អោយមានការយល់ដឹងពីសុខភាពអនាម័យយល់ដឹងពីសញ្ញានានាដែលត្រូវប្រុងប្រយ័ត្ននៅពេលមានផ្ទៃពោះ និងនៅពេលសម្រាលកូន អោយស្ដ្រីមានផ្ទៃពោះគ្រប់រូបទៅពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាពអោយបានពីរដងយ៉ាងតិច និងពង្រឹងសេវាសម្រាលកូននៅមណ្ឌលសុខភាព។ ដោយឡែកបញ្ហាដែលទាក់ទងជាមួយប្រជាពលរដ្ឋដែលមានផ្ទុកជំងឺអេដស៍ កុមារកំព្រាក្រោមអាយុ ១៨ឆ្នាំ ជនពិការ ឃុំមានគោលដៅសហការជាមួយអង្គការស្ថាប័នដែលពាក់ព័ន្ធអោយជួយស្ដាលទ្ធភាពរាងកាយជនពិការ បណ្ដុះបណ្ដាលវិជ្ជាជីវៈ កម្មវិធីផ្ដល់អាហាររូបត្ថ

ម្ត អប់រំសុខភាពបន្តពូជ សុខភាពមាតា និងកុមារ លុបបំបាត់មូលហេតុដែលបណ្តាលអោយមានជំងឺ ចាត់វិធានការបង្ការ និងផ្តល់ការព្យាបាលដែលចាំបាច់ដល់ប្រជាពលរដ្ឋ។

មួយវិញទៀតទាក់ទងទៅនិងបញ្ហាបរិស្ថានវិញ ដើម្បីដោះស្រាយបញ្ហាសុខភាពរបស់ប្រជាជន ឃុំមានទិសដៅអប់រំសុខភាពដល់ប្រជាជនអោយពួកគាត់មានការយល់ដឹងអំពីការរស់នៅស្អាត ហូបស្អាត និងកិច្ចការពារបរិស្ថានផ្សេងៗ។

### ៣.២.៤.ការលើកកម្ពស់គុណភាពអប់រំ

ដើម្បីអភិវឌ្ឍន៍ក្នុងវិស័យអប់រំនៅក្នុងឃុំ ក្រុមប្រឹក្សាឃុំ បានបង្កើនកិច្ចការជាមួយមេភូមិ នាយកសាលា គ្រូបង្រៀន និងមាតាបិតាសិស្ស ពិភាក្សារិះរកមធ្យោបាយក្នុងការជំរុញអោយកុមារទាំងអស់ទៅរៀនជាប្រចាំអោយបានយ៉ាងហោចណាស់ចប់កម្រិតអនុវិទ្យាល័យ ដោយឃុំលើកគម្រោងក្នុងផែនការអភិវឌ្ឍន៍កម្មវិធីវិនិយោគ ផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការរៀនសូត្រក្រេបយកចំនេះដឹងអោយបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅក្នុងឃុំ ដើម្បីអោយពួកគាត់បានយល់ដឹង និងសម្រេចចិត្តនាំកូនអោយមកចុះឈ្មោះចូលរៀន។ លើសពីនេះទៅទៀត ឃុំបានសហការជាមួយស្ថាប័នដែលពាក់ព័ន្ធបង្កើតមតេយ្យសហគមន៍ និងមតេយ្យរដ្ឋ គឺសាងសង់សាលាមតេយ្យក្នុងភូមិត្រពាំងឬស្សី និងសាលាមតេយ្យនៅភូមិចន្ទនិមិត្ត ។ បង្កើតកម្មវិធីផ្គត់ផ្គង់ចំណីអាហារពេលព្រឹកដល់សិស្សមតេយ្យ កំណត់មុខសញ្ញាអោយបានល្អជាងមុនសម្រាប់កម្មវិធីជំរុញការចូលរៀននៅកម្រិតបឋម អោយសាងសង់សាលាបឋមបន្ថែម និងអប់រំផ្សព្វផ្សាយអំពីតម្លៃនៃការសិក្សា និងការអភិវឌ្ឍធនធានមនុស្សឱ្យឪពុកម្តាយរបស់សិស្សបានយល់ដឹងជ្រួតជ្រាបទូទាំងឃុំ មុនបវេសនកាលឆ្នាំសិក្សានីមួយៗ ទំនាក់ទំនងមន្ទីរអប់រំបង្កើនចំនួនគ្រូបង្រៀននៅកម្រិតបឋមសិក្សា ដើម្បីលើកកម្ពស់ផលធៀបសិស្ស និងគ្រូ សាងសង់សាលាបឋមសិក្សានៅតាមភូមិ ដើម្បីអោយប្រជាពលរដ្ឋជាពិសេសសិស្សបានទទួលសេវាគ្រប់គ្រាន់។កាត់បន្ថយចំនាយរបស់សិស្សដែលក្រីក្រតាមរយៈការផ្តល់អាហាររូបករណ៍ (នៅបឋមសិក្សា និងមធ្យមសិក្សា) ពង្រឹងនិងកំណត់មុខសញ្ញាអោយបានល្អជាងមុនសម្រាប់កម្មវិធីផ្តល់អាហារសំរន់នៅបឋមសិក្សា និងកម្មវិធីលើកទឹកចិត្តរបស់សិស្សថ្នាក់ទី ០៧ ដល់ទី ០៩ ។ កាត់បន្ថយអក្ខរជន អោយនៅកម្រិតទាបបំផុត និងឈានទៅបំបាត់នៅពេលខាងមុខ តាមរយៈការធ្វើកិច្ចសហការជាមួយមន្ទីរអប់រំ អង្គការជាតិ និងអន្តរជាតិ ក្នុងការបង្កើតថ្នាក់អក្ខរកម្ម ព្រោះភាពអវិជ្ជមាននៃប្រជាជនវាជាឧបសគ្គសម្រាប់ការអភិវឌ្ឍជីវភាពគ្រួសារ និងសង្គម ។

### ៣.២.៥.ការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់

អនុលោមតាមគោលនយោបាយភូមិឃុំមានសុវត្ថិភាព អាជ្ញាធររដ្ឋបាលភូមិរកាពប្រាំ បានសម្របសម្រួលចាត់តាំង និងដឹកនាំចលនាប្រជាការពារភូមិ ដើម្បីចូលរួមចំណែកក្នុងការការពារសន្តិសុខ

សណ្តាប់ធ្នាប់សាធារណ: និងសុវត្ថិភាពនៅក្នុងមូលដ្ឋានភូមិនីមួយៗ ។ ប្រជាពលរដ្ឋក្នុងភូមិ អាចចូលរួមដោយស្ម័គ្រចិត្តដើម្បីធ្វើជាកំលាំងប្រជាការពារក្នុងភូមិរបស់ខ្លួន ហើយទទួលភារកិច្ចក្នុងការយាមល្បាត ដើម្បីការពារអាយុជីវិត ទ្រព្យសម្បត្តិ និងបង្ការទប់ស្កាត់បទល្មើស ក៏ដូចជាការរៀបចំសណ្តាប់ធ្នាប់នៅក្នុងឃុំផងដែរ ។ គោលដៅចម្បងក្នុងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាពនៅឃុំរកាពប្រាំ គឺធ្វើយ៉ាងណាអោយប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិឃុំ រស់នៅប្រកបដោយសន្តិភាពសន្តិសុខ និងមានសណ្តាប់ធ្នាប់ដោយះ

- គ្មានសកម្មភាព លួច ឆក់ ប្លន់ គ្រប់ប្រភេទ
- គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់
- គ្មានអំពើអនាចារ ការជួញដូរស្ត្រី កុមារ និងអំពើហឹង្សាក្នុងគ្រួសារ
- គ្មានក្មេងទំនើងគ្មានការលេងល្បែងស៊ីសងខុសច្បាប់ និងការប្រើប្រាស់អាវុធខុសច្បាប់គ្រប់ប្រភេទ
- គ្មានគ្រោះថ្នាក់ចរាចរណ៍មានវិធានការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធិភាព
- គ្មានការត្រួតពិនិត្យខុសច្បាប់

### ៣.២.៦.ការបង្កើនប្រសិទ្ធិភាពការងាររដ្ឋបាល និងអភិបាលកិច្ចល្អ

ឃុំបានផ្សព្វផ្សាយការងារអត្រានុកូលដ្ឋាន ការធ្វើសៀវភៅគ្រួសារ ការធ្វើអត្តសញ្ញាណបណ្ណ័សញ្ជាតិខ្មែរ លិខិតបទដ្ឋាននានា ជូនដល់ប្រជាពលរដ្ឋ។ ការសម្រុះសម្រួលទំនាស់ ក្រុមប្រឹក្សាឃុំសម្រុះសម្រួលដោយគតិយុត្តិ គឺជាវិធានការការពារទុកជាមុនដ៏សមស្របបំផុត ដែលឃុំប្រកាន់យកដើម្បីការពារទំនាស់កុំអោយរីករាលដាលខ្លាំងឡើង និងទប់ស្កាត់ក្រុមក្មេងពាល ការប្រើប្រាស់គ្រឿងញៀន និងល្បែងស៊ីសងអោយមានការថយចុះជាបណ្តើរៗ។

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមកដូចយើងបានដឹងរួចមកហើយថាការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ជាការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមបង្អស់ក្នុងប្រព័ន្ធរដ្ឋបាលរបស់ជាតិយើង ហើយជារដ្ឋបាលមួយដែលស្ថិតនៅជាប់ផ្ទាល់ជាមួយប្រជាពលរដ្ឋ ហើយជាការអនុវត្តប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការ ។ លើសពីនេះទៅទៀត ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក៏ជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍប្រទេសជាតិអោយកាន់តែរីកចម្រើន និងមានស្ថេរភាពផងដែរ ។

ការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់មានមូលហេតុ និងសារៈសំខាន់បីយ៉ាងគឺ សំដៅធ្វើអោយឃុំនីមួយៗ អាចម្ចាស់ការគ្រប់គ្រងដោះស្រាយផ្ទាល់រាល់កិច្ចការនៅមូលដ្ឋានបានយ៉ាងឆាប់រហ័ស ទាន់ពេលវេលា ចំទិសដៅនៃបញ្ហា និងអាចប្រើប្រាស់អោយអស់លទ្ធភាពនូវសក្តានុភាពរបស់ខ្លួនផ្ទាល់ គួបផ្សំជាមួយការឧបត្ថម្ភគ្រាំទ្រពីរាជរដ្ឋាភិបាលដើម្បីអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួនអោយកាន់រីកចម្រើន ។ ជាក់ស្តែងនៅឃុំរកាពប្រាំ ប្រជាពលរដ្ឋយើងទទួលបាននូវសិទ្ធិយ៉ាងទូលំទូលាយក្នុងការធ្វើសេចក្តីសម្រេចចិត្តនានាទាក់ទងដល់ការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន ។ មិនត្រឹមតែប៉ុណ្ណោះប្រជាពលរដ្ឋបានចូលរួមផ្តល់មតិយោបល់ ទៅលើកិច្ចការជាច្រើនដែលទាក់ទងទៅនឹងផលប្រយោជន៍របស់ប្រជាពលរដ្ឋខ្លួនឯងផ្ទាល់ ។ រួមជាមួយការចូលរួមរបស់ប្រជាពលរដ្ឋ មន្ត្រី និងក្រុមប្រឹក្សាឃុំ ក៏បានខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួនយ៉ាងយកចិត្តទុកដាក់ ដែលធ្វើអោយកើតឡើងនូវសមិទ្ធផលនានាដូចជា ផ្លូវថ្នល់ សាលារៀន ដោយប្រើប្រាស់មូលនិធិឃុំ រួមជាមួយនិងថវិកាបដិភាគរបស់ប្រជាពលរដ្ឋនៅក្នុងឃុំផងដែរ ។ លើសពីនេះទៅទៀត វិធានការល្អបំផុតនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គឺឈានទៅរកការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ជំរុញកិច្ចអភិវឌ្ឍន៍ខឿនសេដ្ឋកិច្ចយើងដែលបានរងនូវការខូចខាត ខ្ទេចខ្ទាំ ដោយសង្គ្រាមដែលអូសបន្លាយអស់ជាច្រើនទសវត្សរ៍ ។

ដោយឡែកទោះបីជាការគ្រប់គ្រង់រដ្ឋបាលថ្នាក់ឃុំ សង្កាត់ មានលក្ខណៈល្អប្រសើរ និងរលូនទៅមុខក៏ពិតមែនក៏នៅមានចំនុចជាច្រើនដែលខ្វះចន្លោះផងដែរដូចជា ប្រព័ន្ធបច្ចេកទេសនៅមានកម្រិត ខ្វះប្រភពហិរញ្ញវត្ថុដែលជាកត្តាជះឥទ្ធិពលដល់ការអភិវឌ្ឍឃុំ សមាសភាពមន្ត្រីរាជការមិនទាន់សមស្របទៅតាមទំហំឃុំ និងចំនួនប្រជាជនផងដែរ ។

# អនុសាសន៍

បើតាមការស្រាវជ្រាវ និងការជួបប្រទះជាក់ស្តែង ចំពោះការអនុវត្តន៍នូវការគ្រប់គ្រងរដ្ឋបាលរបស់ឃុំ សង្កាត់ យើងខ្ញុំយល់ថាមិនទាន់មានលក្ខណៈល្អនៅឡើយទេ ដោយសារវានៅមានភាពចន្លោះប្រហោងជាច្រើនដែលរដ្ឋាភិបាលគួរយកចិត្តទុកដាក់ និងបំពេញនូវចន្លោះខ្វះខាតទាំងនោះដូចជា៖

- រាជរដ្ឋាភិបាលគួរបើកវគ្គបណ្តុះបណ្តាលមន្ត្រីថ្នាក់ឃុំ សង្កាត់អោយបានច្រើនដងដើម្បីបង្កើនសមត្ថភាពមន្ត្រីរាជការអោយកាន់តែខ្លាំង ជាពិសេសផ្នែកបច្ចេកទេស
- បង្កើនថវិកាក្នុងការអភិវឌ្ឍឃុំ សង្កាត់ឱ្យសមស្របតាមតម្រូវការ ជាពិសេសនោះគឺមូលដ្ឋានដែលក្រីក្រ និងដាច់ស្រយាល
- បង្កើនសមាសភាពមន្ត្រីរាជការអោយសមស្របតាមទំហំឃុំ និងចំនួនប្រជាជនទៅតាមមូលដ្ឋានដើម្បីពួកគាត់ងាយស្រួលធ្វើការងារ និងឆាប់រហ័ស
- ក្រុមប្រឹក្សាឃុំ សង្កាត់គួរតែត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងាររបស់បុគ្គលិកឃុំ សង្កាត់ អំពីការប្រើប្រាស់ឥរិយាបថលើប្រជាពលរដ្ឋថាតើសមគួរដែល ឬទេ នៅពេលប្រជាពលរដ្ឋមកទទួលសេវា ឬសាកសួរពត៌មាន។

# គន្ថនិទ្ទេស


## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ ២០០៦។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ ២០០១។

អនុក្រឹត្យលេខ ១៦ អនក្រ/បក ស្តីពីមូលនិធិឃុំ សង្កាត់ឆ្នាំ ២០០២។

អនុក្រឹត្យលេខ ២២ អនក្រ/បក ស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅអោយក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ ២០០២។

អនុក្រឹត្យលេខ ២៦ អនក្រ/បក ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់ឆ្នាំ ២០០២។

## សៀវភៅ

ក្រសួងមហាផ្ទៃ.ឆ្នាំ២០១៧.*ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ*។

ក្រសួងមហាផ្ទៃ.ឆ្នាំ២០០៧.*ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ*។

អនុបណ្ឌិត ហៀង សាង.ឆ្នាំ២០១១.*នីតិរដ្ឋបាលទូទៅ*។

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហាមជ្ឈការ.ឆ្នាំ២០០៧.*ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ*។

## ឯកសារផ្សេងៗ

កម្មវិធីវិនិយោគឃុំឆ្នាំ២០១៦, ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

ផែនការអភិវឌ្ឍន៍ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំឆ្នាំ ២០១៦។